**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# លក្ខណៈពិសេសរបស់បណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

តាក់តែងឡើងដោយ
និស្សិតឈ្មោះ: **ភញ្ញា នូ រតនា**

សាស្ត្រាចារ្យណែនាំ
**លោក រុន ពណ្ណារិទ្ធ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤
ឆ្នាំសរសេរសារណា ២០១៨

# អារម្ភកថា

លក្ខណៈពិសេសរបស់បណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌ សិក្សាពិសេសទៅលើការជួសជុលព្យសនកម្ម ដែលបានកើតឡើងពីអំពើបំពានរបស់ជនល្មើស លើសិទ្ធិ និងទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ដែលរមែងផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ របស់បុគ្គលម្នាក់ៗ នៅក្នុងសង្គម ដោយមិនគិតពី ប្រពៃណី ជាតិសាសន៍ ភេទ ឋានៈ តួនាទី ឬ ពណ៌សម្បុរ អ្វីឡើយ ។

ការជ្រើសរើសប្រធានបទ **លក្ខណៈពិសេសរបស់បណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌ** ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ នាងខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំងដែលទទួលបានការណែនាំពីលោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ក្នុងការស្រាវជ្រាវលើប្រធានបទមួយនេះ ហើយនាងខ្ញុំសង្ឃឹមថា ស្នាដៃមួយនេះនឹងក្លាយជាប្រយោជន៍ក្នុងតម្រូវការរបស់អ្នកអាន ដែលមានបំណងចង់ស្វែងយល់ ចង់ដឹង ជុំវិញបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលជានិច្ចកាលគឺតែងតែកើតមានឡើងជារឿយៗក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សម្នាក់ៗ។ លើសពីនេះទៅទៀតអ្នករៀបរៀងមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងក្នុងការទទួលយកនូវមតិរិះគន់ពីគ្រប់មជ្ឈដ្ឋាន ចំពោះខ្លឹមសារ ពាក្យពេចន៍ និងចំណុចខុសឆ្គងដែលមានក្នុងសារណានេះ ដើម្បីជួយជម្រុញ ពង្រឹង ក្នុងន័យស្ថាបនាកែលម្អឱ្យកាន់តែល្អប្រសើរ។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **នូ រតនា** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖

-លោកឪពុក **នូ ថានី** និង អ្នកម្តាយ **ហ៊ីយ គីមហុង** លោកទាំងពីរជាអ្នកមានគុណដ៏ធំធេងបំផុតដែលបានផ្តល់កំណើត ហើយថែមទាំងបានខិតខំប្រឹងប្រែង ពុះពារគ្រប់ឧបសគ្គ មិនថាក្តៅ ឬត្រជាក់ ដោយមិនគិតពីការនឿយហត់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ទាំង៤ ដល់រូបកូនឱ្យក្លាយជា កូនល្អ សិស្សល្អ និងជាពលរដ្ឋល្អនៅក្នុងសង្គម ។

-**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជាប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដែលជានិច្ចកាលតែងតែខិតខំប្រឹងប្រែងយ៉ាងប្តូរផ្តាច់ជាទីបំផុតដើម្បីធ្វើយ៉ាងណាឱ្យប្រទេសកម្ពុជាទទួលបាននូវ សុខសន្តិភាព សុវត្ថិភាព ស្ថិរភាព និងការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ ដូចជាការកសាងសាលារៀន វត្តអារាម ស្ពាន ផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដទៃទៀតជាច្រើន កត្តាទាំងនេះហើយដែលបានផ្តល់នូវឱកាសដ៏មានតម្លៃសម្រាប់រូបនាងខ្ញុំផ្ទាល់ ក៏ដូចជាប្រជាពលរដ្ឋដទៃទៀត ក្នុងការក្រេបជញ្ជក់យកនូវចំណេះដឹង ព្រមទាំងមានឱកាសបានអភិវឌ្ឍន៍ចំណេះដឹងរបស់ខ្លួនឱ្យបានកាន់តែប្រសើរបន្ថែមទៀត ។

-ឯកឧត្តម **លុយ ចន្ធូា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច លោកសាកលវិទ្យាធិការរង និងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ លោក លោកស្រីសាស្ត្រាចារ្យ ព្រមទាំងមន្ត្រីរាជការ បុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យ ដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្តល់នូវចំណេះដឹង ក៏ដូចជាចែករំលែកបទពិសោធន៍ល្អៗ ប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌ខ្ពស់ ដល់រូបនាងខ្ញុំ ក្នុងរយៈពេល ប្រមាណជិត ០៤ឆ្នាំកន្លងមកនេះ ។

-លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ព្រឹទ្ធបុរស នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងជាសាស្ត្រាចារ្យដឹកនាំស្រាវជ្រាវចំពោះប្រធានបទសារណាបញ្ចប់ការសិក្សាមួយនេះ ហើយបានចែករំលែកនូវ ចំណេះដឹង សេចក្តីស្រលាញ់ ការអប់រំទូន្មានប្រៀនប្រដៅ ដែលមិនចេះរីងស្ងួត និងមិនគិតពីការនឿយហត់ ដើម្បីធ្វើយ៉ាងណាឱ្យនិស្សិតទទួលបាននូវចំណេះដឹង ក្រមសីលធម៌ ចំណេះធ្វើ បទពិសោធន៍ ដើម្បីក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អនិងជាធនធានមនុស្សនៅក្នុងសង្គម និង លោកស្រីសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ដែលបានព្យាយាមចំណាយពេលវេលាផ្ទាល់ខ្លួន ទោះបីជាមានការមមាញឹកយ៉ាងណាក៏ដោយ ដើម្បីជួយបណ្តុះប

ណ្ដាលរូបនាងខ្ញុំ ដើម្បីបានចងក្រងនូវស្នាដៃមួយនេះក្រោមការពិនិត្យដោយយកចិត្តទុកដាក់បំផុត ។

-លោក **អ៊ុច គឹមស្រ៊ី** ចៅក្រមតុលាការកំពូល ដែលបានអនុញ្ញាតឱ្យនាងខ្ញុំមានពេលវេលាបានសិក្សាស្រាវជ្រាវ ហើយព្រមទាំងជួយលើកទឹកចិត្ត និងចង្អុលបង្ហាញ អប់រំទូន្មាន ប្រៀនប្រដៅពន្យល់ ដោយពុំគិតពីភាពនឿយហត់ ទោះជាលោកមានភាពមមាញឹកខ្លាំងយ៉ាងណាក៏ដោយ នាងខ្ញុំពិតជាចងចាំជានិច្ចនូវទឹកចិត្តដ៏ល្អថ្លៃថ្លារបស់លោក ទាំងការបង្ហាត់បង្រៀន និងការអប់រំទូន្មានប្រៀនប្រដៅ ក្នុងគោលបំណងឱ្យក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គម រៀងរហូតទៅ។

-រៀមច្បង រួមទាំងមិត្តនិស្សិតរួមជំនាន់ទាំងអស់ ដែលបានជ្រោមជ្រែងយ៉ាងសកម្មក្នុងការផ្តល់កម្លាំងចិត្ត ដើម្បីជម្រុញឱ្យស្នាដៃអត្ថបទមួយនេះល្អប្រសើរ ។

ជាចុងក្រោយនេះ នាងខ្ញុំមានកិត្តិយសសូមបន្ទន់កាយលើកដៃប្រណម្យបួងសួង គោរពជូនដល់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រី មេត្តាទទួលយកដោយសេចក្តីអនុគ្រោះបំផុត នូវភក្តីភាពគោរពស្រលាញ់យ៉ាងស្មោះត្រង់បំផុត និងសូមឱ្យបានជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លៀតឡើយ ។ ទន្ទឹមនឹងនេះ នាងខ្ញុំសូមបួងសួងដល់វត្ថុសក្តិសិទ្ធិក្នុងលោក ជួយថែរក្សា ការពារ ដល់ លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ បុគ្គលិក មិត្តភក្តិ និង ប្រជាពលរដ្ឋខ្មែរទាំងអស់ ឱ្យបានជួបប្រទះតែភាពសុខដុមរមនា សុខសន្តិភាព មានសុខភាពល្អ ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ និង ពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លៀតឡើយ ។

# មាតិកា

**សេចក្តីផ្តើម** ........................................ ១

**ផ្នែកទី១. សញ្ញាណទូទៅនៃបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌ** ........................................ ២

កថាខណ្ឌទី១. មូលហេតុដែលនាំឱ្យមានបណ្តឹងរដ្ឋប្បវេណី ........................................ ២

កថាខណ្ឌទី២. គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី ........................................ ៣

កថាខណ្ឌទី៣. មូលដ្ឋានផ្នែកច្បាប់នៃការធ្វើបណ្តឹងរដ្ឋប្បវេណី ........................................ ៤

**ផ្នែកទី២. ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី** ........................................ ៦

កថាខណ្ឌទី១. ដំណាក់កាលនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ........................................ ៦

កថាខណ្ឌទី២. អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី ........................................ ១៤

**ផ្នែកទី៣. ភាគីនៃបណ្តឹងរដ្ឋប្បវេណី** ........................................ ១៥

កថាខណ្ឌទី១. ដើមបណ្តឹងរដ្ឋប្បវេណី ........................................ ១៥

១.១. ជនរងគ្រោះផ្ទាល់នៃបទល្មើស ឬតំណាងស្របច្បាប់ ........................................ ១៥

១.២. សិទ្ធិវន្តរបស់ជនរងគ្រោះ ........................................ ១៥

១.៣. សមាគមដែលបំពេញតាមលក្ខខណ្ឌច្បាប់ ........................................ ១៦

កថាខណ្ឌទី២. អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី ........................................ ១៧

២.១. ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ........................................ ១៧

២.២. អ្នកទទួលខុសត្រូវរដ្ឋប្បវេណីផ្សេងទៀត ........................................ ១៩

**ផ្នែកទី៤. ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងរដ្ឋប្បវេណី** ........................................ ២១

កថាខណ្ឌទី១. បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ........................................ ២១

កថាខណ្ឌទី២. បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម ........................................ ២៤

កថាខណ្ឌទី៣. បណ្តឹងទាស់ចំពោះសាលដីការបស់សាលាឧទ្ធរណ៍ចេញដោយកំបាំងមុខ ........................................ ៣០

កថាខណ្ឌទី៤. បណ្តឹងសាទុក្ខ ........................................ ៣២

**ផ្នែកទី៥. ការបង្ខំដល់រូបកាយ** ........................................ ៣៩

កថាខណ្ឌទី១៖ មូលហេតុនៃការបង្ខំដល់រូបកាយ ........................................ ៣៩

១.១. ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនីតិវិធី ........................................ ៣៩

១.២. ការបង្ខំដល់រូបកាយតាមពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........................................ ៤០

កថាខណ្ឌទី២៖ ការរួចខ្លួនពីការបង្ខំដល់រូបកាយ និងការដោះលែងឱ្យមានសេរីភាពវិញ ........................................................................................................................ ៤១
១.១.ការរួចខ្លួនពីការបង្ខំដល់រូបកាយ ............................................................ ៤១
១.២.ការដោះលែងឱ្យមានសេរីភាពវិញ........................................................ ៤១
**សេចក្តីសន្និដ្ឋាន**........................................................................................... **៤៣**
**អនុសាសន៍**.................................................................................................... **៤៤**
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# អក្សរកាត់

អ.វ.ត.ក ៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

# សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន មានច្បាប់ដែលកំពុងនៅជាធរមានជាច្រើន ដែលក្នុងនោះ យើងសង្កេតឃើញថា ច្បាប់ដែលមន្ត្រីអនុវត្តច្បាប់កំពុងពង្រឹងនោះគឺ ច្បាប់ព្រហ្មទណ្ឌ។ ច្បាប់ព្រហ្មទណ្ឌមានមុខងារក្នុងការបង្ក្រាបបទល្មើស បង្ការបទល្មើស អប់រំជនល្មើសឱ្យចូលទៅក្នុងសង្គមវិញ។

បទល្មើសដែលបានប្រព្រឹត្តដោយជនល្មើស វាតែងតែបង្កឱ្យមានព្យសនកម្មទាំងរូបរាងកាយ ព្យសនកម្មផ្លូវចិត្ត និងព្យសនៈកម្មសម្ភារៈ បំពានទៅលើជនរងគ្រោះ ។ ជាលទ្ធផលអំពើព្យសនកម្មទាំងនេះ អាចបង្កឱ្យមានការប៉ះពាល់ដល់រូបរាងកាយ និង ខូចខាតដល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ហើយបុគ្គលគ្រប់រូបដែលទទួលរងនូវព្យសនកម្មពីបទល្មើសអាចដាក់ពាក្យ តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធ្វើការទាមទារសំណងរបស់ខ្លួនបាន ដោយផ្អែកលើព្យសនកម្មដែលខ្លួនបានខាតបង់ដោយអំពើបំពានទាំងនោះ ហើយមានភស្តុតាងជាក់លាក់ ដើម្បីទាមទារសំណងឱ្យធួនល្មមទៅនឹងព្យសនកម្មដែលបានកើតឡើង ។

ជាចំណេះដឹងផ្នែកច្បាប់សម្រាប់សាធារណជន សម្រាប់ជាមូលដ្ឋានក្នុងការយល់ដឹងពីសិទ្ធិរបស់ខ្លួនក្នុងការទាមទារសំណងជម្ងឺចិត្ត និងសំណងការខូចចិត្តផ្សេងៗដែលកើតឡើងដោយសារបទល្មើស។

ចំពោះការបកស្រាយលើប្រធានបទនេះឱ្យបានច្បាស់លាស់ និងក្បោះក្បាយដើម្បីជាចំណេះដឹងផ្នែកច្បាប់សម្រាប់សាធារណជន សម្រាប់ជាមូលដ្ឋានក្នុងការយល់ដឹងពីសិទ្ធិរបស់ខ្លួនក្នុងការទាមទារសំណងជម្ងឺចិត្ត និងសំណងការខូចចិត្តផ្សេងៗដែលកើតឡើងដោយសារ បទល្មើស នាងខ្ញុំបានធ្វើការបែងចែកជា០៥ (ប្រាំ) ផ្នែកគឺ **ផ្នែកទី១៖ សញ្ញាណទូទៅនៃបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌ ផ្នែកទី២៖ ភាគីនៃបណ្តឹងរដ្ឋប្បវេណី ផ្នែកទី៣៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ផ្នែកទី៤៖ ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងរដ្ឋប្បវេណី និង ផ្នែកទី៥៖ ការបង្ខំដល់រូបកាយ ។**

## ផ្នែកទី ១ ៖ សញ្ញាណទូទៅនៃបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌ

រាល់អំពើបំពានច្បាប់ រមែងតែមានការប៉ះពាល់ដល់សង្គមជាតិ ប៉ុន្តែកម្រិតនៃមហន្តរាយមានទំហំខុសៗគ្នា។ ដូចនេះទាមទារឱ្យរដ្ឋមានវិធានការដោះស្រាយសមស្របចំពោះបណ្តាលអំពើទាំងអស់នោះ។ ជាមួយនឹងអំពើបំពានច្បាប់បង្កឱ្យអន្តរាយតិចតួច រដ្ឋប្រើប្រាស់នូវវិធានការធូនល្មមដើម្បីស្តារឡើងវិញនូវទំនាក់ទំនងសង្គម និងបណ្តាលបទដ្ឋានដែលត្រូវបានបំពាន។ ប៉ុន្តែចំពោះអំពើរំលោភបំពាន ដែលមានចរិតគ្រោះថ្នាក់ខ្លាំងក្លាបង្កការមហន្តរាយធ្ងន់ធ្ងរនោះត្រូវអនុវត្តវិធានការតឹងតែងដើម្បីផ្តន្ទាទោសចំពោះជនដែលប្រព្រឹត្តអំពើនោះ។ ទន្ទឹមនឹងនេះ រដ្ឋមានវិធានការអប់រំជនល្មើស និងបង្ការនូវអំពើល្មើសទាំងនោះផងដែរ។ លើសពីនេះទៅទៀត រាល់អំពើបំពានច្បាប់ដែលជាបទល្មើសខ្លះបានបង្កឱ្យមានគ្រោះថ្នាក់ ប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់បុគ្គល។ អំពើបំពានទាំងនេះអាចបណ្តាលឱ្យមានការខូចខាតដូចជា ការខូចខាតខាងសម្ភារ ខាងរូបកាយ ឬខាងផ្លូវចិត្ត។ គួរកត់សម្គាល់ផងដែរ រាល់អំពើបំពានដល់សិទ្ធិ ឬផលប្រយោជន៍ទាំងនោះមិនមែនសុទ្ធសឹងតែជាបទល្មើសទេ។

### កថាខណ្ឌទី ១ ៖ មូលហេតុដែលនាំឱ្យមានបណ្តឹងរដ្ឋប្បវេណី

ពេលនិយាយដល់បណ្តឹងរដ្ឋប្បវេណី គឺតែងតែនឹកឃើញដល់បណ្តឹងដែលទាមទារនូវសំណងនៅក្នុងទំនាក់ទំនងឯកជនរបស់បុគ្គល។ ផ្ទុយទៅវិញ បណ្តឹងរដ្ឋប្បវេណីក្នុងន័យនេះ សំដៅលើបណ្តឹងដែលប្តឹងទាមទារនូវសំណងការខូតខាតដែលបានកើតពីបទល្មើស។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បានកំណត់អំពីនិយមន័យ និងចំណាត់ថ្នាក់នៃបទល្មើសថា "អំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គម ជាបទល្មើស។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ" ។[1] ដោយយោងទៅតាមអត្ថន័យនៃមាត្រា ២ នៃក្រមនេះ ត្រង់ឃ្លា "ដែលបង្កចលាចលដល់សង្គម" មានន័យថា បង្កឲ្យមានការខូចខាតដល់សណ្តាប់ធ្នាប់សាធារណៈ ទំនៀមទម្លាប់ល្អ និង សិទ្ធិ និង ប្រយោជន៍របស់បុគ្គលរបស់រូបវន្តបុគ្គល និង នីតិបុគ្គល។ ដូច្នេះ នៅពេលមានបទល្មើសកើតឡើង គឺចាំបាច់ត្រូវមាន បណ្តឹងដែលប្រឆាំងនឹងបទល្មើសនោះ គឺបណ្តឹងអាជ្ញា ដែលធ្វើឡើងដោយតំណាងអយ្យការក្នុងនាមជាអ្នកការពារដល់ផលប្រយោជន៍សាធារណៈ។ ម្យ៉ាងវិញទៀត កាលណានៅក្នុងបទល្មើសនោះ មានការបង្កឲ្យមានគ្រោះថ្នាក់ បំពានសិទ្ធិ ឬ ផលប្រយោជន៍របស់បុគ្គលណាមួយនៅក្នុងបទល្មើសដដែលនោះនឹងអាចមានបណ្តឹងមួយទៀត ដែលកើតឡើងពីការកើតទុក្ខមិនសុខ

[1] ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ មាត្រា ២

ចិត្ត ដែលនាំឱ្យមានបណ្តឹងទាមទារនូវសំណងការខូចខាតដែលបណ្តឹងនោះហៅថា បណ្តឹងរដ្ឋប្បវេណី ។

## **កថាខណ្ឌទី ២ ៖ គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី**

បណ្តឹងរដ្ឋប្បវេណី មានគោលបំណងធ្វើឱ្យ បានជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឱ្យអ្នករងគ្រោះបានទទួលសំណងជម្ងឺចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល។[2] ព្យសនកម្មអាចជាព្យសនកម្ម ខាងសម្ភារៈ ខាងរូបកាយ ឬខាងផ្លូវចិត្ត។[3]

### **ចំណុចទី ១ ៖ ព្យសនកម្មផ្នែកសម្ភារៈ**

នៅពេលដែលជនល្មើសបានប្រព្រឹត្តបទល្មើស អំពើរបស់ជនល្មើសបណ្តាលឱ្យមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងមានការខូចខាតច្រើន ដែលអំពើនេះបង្កឱ្យមានព្យសនកម្មផ្នែកសម្ភារៈដល់ជនរងគ្រោះ។ ករណីនេះជនរងគ្រោះអាចទាមទារសំណងដើម្បីជួសជុលព្យសនកម្ម ដែលខ្លួនបានទទួលដោយសារព្យសនកម្មដែលបានបង្កនោះ។

ព្យសនកម្មផ្នែកសម្ភារៈ រួមបញ្ចូលទាំងការបាត់បង់ទ្រព្យសម្បត្តិ ឬចំណូល។ ព្យសនកម្មនេះអាចធ្វើការទាមទារបានទៅតាមទំហំនៃការខូចខាត។ ចំពោះព្យសនកម្មលើសម្ភារៈ គេមិនត្រឹមតែរាប់បញ្ចូលនូវព្យសនកម្មដោយផ្ទាល់ប៉ុណ្ណោះទេ តែគេថែមទាំងយល់ឃើញថា ព្យសនកម្មដែលបង្កឱ្យមានការប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់តួសម្តែង និង សិល្បករ ជាដើម។ ការខូចខាតបែបនេះ វាអាចជះឥទ្ធិពលដល់ការធ្វើការប្រកបវិជ្ជាជីវៈរបស់ពួកគេ និងអាចបណ្តាលឱ្យពួកគេបាត់បង់វិជ្ជាជីវៈក៏ដូចជាបាត់បង់ចំណូលសម្រាប់ចិញ្ចឹមជីវិតរបស់ពួកគេផងដែរ។

សម្រាប់តុលាការ ប្រហែលជាមិនទាន់ទទួលស្គាល់ការខូចខាតបែបនេះទេ តែសម្រាប់តុលាការបារាំងវិញ បានទទួលស្គាល់ និងសម្រេចឱ្យមានការជួសជុលសំណងធ្លាប់បានធ្វើរួចទៅហើយ។ ចំពោះការអនុវត្តក្នុងការទាមទារ ជនរងគ្រោះភាគច្រើនតែងតែធ្វើការទាមទារសំណងខូចខាតរបស់ខ្លួនត្រឡប់មកវិញនៅចំពោះមុខតុលាការ ប៉ុន្តែក៏មានជនរងគ្រោះមួយចំនួនមិនបានទាមទារឱ្យមានសំណងការខូចខាតនោះទេ។

---

[2] ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌទី ៣ មាត្រា ២

[3] ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ មាត្រា ១៣

### ចំណុចទី ២ ៖ ព្យសនកម្មផ្នែករូបរាងកាយ

ព្យសនកម្មលើរូបរាងកាយ និងសំភារៈ គឺជាព្យសនកម្មដែលងាយស្រួលយល់ និងអាចប៉ាន់ប្រមាណបាន ដោយអាចដឹងពីទំហំនៃព្យសនកម្មដែលអាចងាយស្រួលនៅក្នុងការធ្វើការជួសជុលព្យសនកម្មដែលបានកើតឡើងនោះ ប្រសិនជាប្រៀបធៀបជាមួយព្យសនកម្មផ្លូវចិត្ត។

### ក. ការកំណត់អំពីព្យសនកម្មរូបរាងកាយ

ព្យសនកម្មលើរូបរាងកាយ គឺជាការខូចខាត ឬ ការប៉ះពាល់ដែលធ្វើឱ្យមានរបួសស្នាម បាក់ខូចរាងកាយមនុស្ស ទោះជាធ្ងន់ ឬ ស្រាល ក៏ដោយ។ ព្យសនកម្មប្រភេទនេះអាចធ្វើការវាយតម្លៃបានតាមរយៈការភ្ជាប់ជាមួយឯកសារថ្លៃចំណាយនានា ឬ លិខិតបញ្ជាក់ពីអ្នកជំនាញបាន ដើម្បីអាចឱ្យតុលាការធ្វើការវាយតម្លៃ។

**ឧទាហរណ៍ ៖** បទល្មើសការបង្ករបួសស្នាម គឺព្យសនកម្មកើតឡើងទៅលើរូបរាងកាយជនរងគ្រោះ ហើយការកំណត់របួសធ្ងន់ ឬ ស្រាល គឺអាចប្រើប្រាស់ការធ្វើកោសលវិច័យ ដែលមានគ្រូពេទ្យជំនាញ មកបញ្ជាក់ពីទំហំនៃការខូចខាត ឬ តម្លៃទ្រព្យសម្បត្តិ។

### ចំណុចទី ៣ ៖ ព្យសនកម្មផ្លូវចិត្ត

ព្យសនកម្មផ្លូវចិត្ត ជាប្រភេទដែលពិបាកធ្វើការកំណត់សម្គាល់ និងអាចបង្ហាញឱ្យបានដឹងថាតើព្យសនកម្មបែបនេះស្ថិតក្នុងកម្រិតបែបណា និងគោរពតាមបទដ្ឋានណាដែរ ដើម្បីអាចយកជាមូលដ្ឋានសម្រាប់ចៅក្រមក្នុងការវាយតម្លៃបាន។ ដូច្នេះទាមទារមានការកំណត់ឱ្យបានជាក់លាក់ពីអ្នកជំនាញ និង អាស្រ័យទៅតាមកាលៈទេសៈនៅជុំវិញកត្តាដែលបណ្តាលឱ្យមានការខូចខាត។ ព្យសនកម្មផ្លូវចិត្តអាចរួមបញ្ចូល វិបល្លាសស្មារតី ឬជម្ងឺផ្លូវចិត្ត ឬសតិអារម្មណ៍លើផ្លូវចិត្តរបស់ជនរងគ្រោះ ដូចជា ជម្ងឺបាក់ស្បាត ជាអាទិ៍។ សំណងជម្ងឺចិត្តក៏ចាត់ទុកជាការជួសជុលព្យសនកម្មផងដែរ គឺការជួសជុលព្យសនកម្មខាងផ្លូវចិត្ត។ នៅពេលដែលអំពើល្មើសមួយកើតឡើង វាមិនត្រឹមតែបង្កនូវគ្រោះថ្នាក់ និងការខូចខាតដល់រូបរាងកាយ និងទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ឬ ក្រុមគ្រួសាររបស់ជនរងគ្រោះប៉ុណ្ណោះទេ តែក៏អាចបង្កជាវិបត្តិផ្នែកផ្លូវចិត្ត ដែលអាចបន្សល់ទុកដល់ជនរងគ្រោះនៅថ្ងៃមុខថែមទៀតផង។

## កថាខណ្ឌទី ៣ ៖ មូលដ្ឋានផ្នែកច្បាប់នៃការធ្វើបណ្តឹងរដ្ឋប្បវេណី

ដោយសារបណ្តឹងរដ្ឋប្បវេណី ជាបណ្តឹងដែលធ្វើឡើងដោយបុគ្គលឯកជន ដូច្នេះ មូលដ្ឋាននៃការធ្វើបណ្តឹងរដ្ឋប្បវេណីនេះ គឺអនុវត្តតាមបទដ្ឋានគតិយុត្តដែលកំណត់អំពីទំនាក់ទំនងរបស់បុគ្គលឯកជន។ យោងតាមមាត្រា១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ បានចែងថា "ក្រមនេះបញ្ញត្តអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី។

បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ ត្រូវយកមកអនុវត្ត ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេង នៅក្នុងច្បាប់ពិសេស។” នៅក្នុងក្រមនេះ មានចំណុចជាច្រើនដែលពាក់ព័ន្ធនឹងទំនាក់ទំនងទ្រព្យសម្បត្តិ ក៏ប៉ុន្តែមានគន្លឹះមួយដែលពាក់ព័ន្ធនឹងទំនាក់ទំនងទ្រព្យសម្បត្តិ ហើយជាមូលដ្ឋាននៃការធ្វើបណ្តឹងរដ្ឋប្បវេណី គឺ គន្លឹះទី៥ ជំពូកទី ១៦ “**អំពើអនីត្យានុកូល**” ។

## ផ្នែកទី ២ ៖ ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

ការធ្វើបណ្តឹងរដ្ឋប្បវេណី គឺជាការអនុវត្តសិទ្ធិទាមទារតាមផ្លូវតុលាការចំពោះវិវាទទាំងឡាយណា ដែលពាក់ព័ន្ធនឹងទំនាក់ទំនងញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិ ដូចជាបណ្តឹងលែងលះ បណ្តឹងទាមទារដី ឬប្រាក់ជាអាទិ៍។ បណ្តឹងរដ្ឋប្បវេណីត្រូវទៅតុលាការរដ្ឋប្បវេណី នៃការិយាល័យទទួលពាក្យបណ្តឹង និង រដ្ឋបាលរបស់សាលាដំបូងរាជធានី-ខេត្ត ដោយភាគីនៃសំណុំរឿងហៅថាដើមបណ្តឹងរដ្ឋប្បវេណី (អ្នកប្តឹងគេ) និង អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី (អ្នកដែលត្រូវគេប្តឹង) ។ នៅពេលដាក់ពាក្យបណ្តឹងត្រូវបង់ពន្ធ (ពន្ធដាក់ពាក្យសុំ) ដោយសមាមាត្រទៅតាមតម្លៃកម្មវត្ថុនៃបណ្តឹង ហើយតុលាការនឹងបោះត្រាបញ្ជាក់។

### កថាខណ្ឌទី ១ ៖ ដំណាក់កាលនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

បណ្តឹងរដ្ឋប្បវេណីអាចធ្វើឡើងបានពីររបៀបគឺ ទី១៖អាចធ្វើឡើងនៅពេលជាមួយគ្នានឹងបណ្តឹងអាជ្ញានៅចំពោះមុខតុលាការព្រហ្មទណ្ឌ ឬទី២៖ បណ្តឹងនេះក៏អាចធ្វើបានផងដែរនៅ ចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី ដែលក្នុករណីនេះបណ្តឹងនេះត្រូវព្យួរសិន ដរាបណានៅមិនទាន់មានសេចក្តីសម្រេចណាជាស្ថាពរមួយត្រូវបានប្រកាសលើបណ្តឹងអាជ្ញា។[4] យ៉ាងណាមិញ នាងខ្ញុំនឹងបកស្រាយតែចំណុចទី១ តាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ដែលធ្វើឡើងជាមួយគ្នានឹងបណ្តឹងអាជ្ញា អាចធ្វើនៅចំពោះមុខចៅក្រមស៊ើបសួរ ក្នុងដំណាក់កាលជំនុំជម្រះតែប៉ុណ្ណោះ។

**ដំណាក់កាលស៊ើបអង្កេត** កំណត់ហេតុនៃបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ទទួលបណ្តឹងទាមទារ និងបណ្តឹងបរិហារ។ មន្ត្រីនគរបាលយុត្តិធម៌ពិនិត្យបទល្មើសទាំងឡាយ។ មន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេតបទល្មើសជាក់ស្តែង និងធ្វើការស៊ើបអង្កេតបឋមក្នុងលក្ខខណ្ឌនៃមាត្រា ៨៤ (ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តធម៌ទៅតាមការស៊ើបអង្កេត) ដល់មាត្រា ១១០ (អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម) នៃក្រមនេះ។

កាលណាការស៊ើបសួរបានចាប់ផ្តើម មន្ត្រីនគរបាលយុត្តិធម៌ អនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរ នៅក្នុងលក្ខខណ្ឌដែលបានចែងដោយមាត្រា ១៧៣ (ដីកាចាត់ឱ្យស៊ើបសួរជំនួស) ដល់មាត្រា ១៨៤ (កំណត់ហេតុកសាងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនេះ ។[5]

**កំណត់ហេតុ** គ្រប់បណ្តឹងដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌នោះ តម្រូវឱ្យមានធ្វើកំណត់ហេតុ។ កំណត់ហេតុត្រូវស្រង់ដោយត្រឹមត្រូវនូវសេចក្តីរាយការណ៍របស់អ្នកប្តឹង។ ក្នុងករណី

[4] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ២៣
[5] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៧១

ចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅរកអ្នកបកប្រែភាសាម្នាក់ដែលត្រូវស្បថតាមជំនឿ ឬសាសនាថា ខ្លួននឹងបកប្រែភាសាឱ្យបានត្រឹមត្រូវតាមសេចក្តីរាយការណ៍។ នៅក្នុងករណីណាក៏ដោយអ្នកបកប្រែភាសាមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថដែលជាកងកម្លាំងរួមប្រតិបត្តិការបានឡើយ។ កំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងត្រូវមានចុះសេចក្តីដូចតទៅ:

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

-កាលបរិច្ឆេទ

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអ្នកប្តឹង ។

ការឆូត ការថែម និងការយោង ត្រូវតែមានបញ្ជាក់ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹង នៅរឹមទំព័រ។

មុននឹងចុះហត្ថលេខា ឬ ផ្តិតម្រាមដៃ អ្នកប្តឹងត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានខ្លឹមសារកំណត់ហេតុដោយសំឡេងខ្លាំងៗ ។[6]

នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវតែមានបញ្ជីបណ្តឹងមួយ ។ នៅគ្រប់ពេលដែលមានការដាក់ពាក្យប្តឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងបញ្ជីនូវនិទ្ទេសដូចតទៅ:

-អត្តសញ្ញាណរបស់អ្នកប្តឹង

-កាលបរិច្ឆេទនៃការដាក់ពាក្យប្តឹង

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹង

-ប្រភេទនៃអំពើដែលប្តឹង

-ចំណាត់ការលើបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬ ក៏ផ្តើមធ្វើការស៊ើបអង្កេតបញ្ជីបណ្តឹងត្រូវតែកាន់កាប់ជាអចិន្ត្រៃសម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។[7]

**ចំណាត់ការបន្តពីការដាក់ពាក្យប្តឹង** មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបណ្តឹងនោះ ត្រូវតែចាប់ផ្តើមភ្លាមៗ ធ្វើការស៊ើបអង្កេត ឬ ក៏បញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យប្តឹងនោះ ទៅព្រះរាជអាជ្ញាដើម្បីចាត់ការតទៅ។ មន្ត្រីនគរបាលយុត្តិធម៌ មុនធ្វើការស៊ើបអង្កេត អាចសុំសេចក្តីណែនាំពី

[6] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៧២

[7]ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៧៣

ព្រះរាជអាជ្ញា។ កាលណាទទួលពាក្យប្ដឹងបរិហារ ដែលមានបង្ហាញមូលហេតុជាក់ច្បាស់សមហេតុផលមន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ។[8]

**ដំណាក់កាលស៊ើបសួរ** កាលណាការស៊ើបសួរត្រូវបានបើកបុគ្គលគ្រប់រូបដែលបានប្រកាសថាខ្លួនជាជនរងគ្រោះ អាចតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា។[9]

**ការតាំងខ្លួននៅកាលបរិច្ឆេទនៃនីតិវិធី** ការកំណត់ពីអត្តសញ្ញាណដំបូង នៃការខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងកាលបរិច្ឆេទនៃការស៊ើបសួរ មិនបានចែងឱ្យជាក់លាក់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរត្រង់ មាត្រា១៣៧ នោះទេ ប៉ុន្តែជាទូទៅក្នុងការអនុវត្តនាពេលកន្លងមក នៅសាលាដំបូងបានអនុវត្តដូចមានចែងក្នុងវិធានផ្ទៃក្នុងតុលាការ អ.វ.ត.ក ក្នុងការកំណត់ភាពអាចទទួលយកបាននៃអ្នកតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដូចជា៖[10]

១. បង្ហាញពីអត្តសញ្ញាណឱ្យបានច្បាស់លាស់ និង

២. បង្ហាញពីលទ្ធផលដោយផ្ទាល់ពីបទល្មើស ដែលត្រូវបានចោទប្រកាន់លើជនត្រូវចោទថាខ្លួនពិតជាបានទទួលរងព្យសនកម្មខាងរូបកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលអាចជាមូលដ្ឋានសម្រាប់សម្រាប់ការទាមទារសំណងផ្លូវចិត្ត និងទទួលសំណងជាសមូហភាព (អនុវត្តតែនៅអ.វ.ត.ក) ។

បន្ទាប់ពីចៅក្រមបានធ្វើការពិចារណា អំពីភាពអាចទទួលយកបាន នៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវតែមានជំនឿថាអង្គហេតុដែលគាំទ្រដល់ការដាក់ពាក្យសុំ នោះមានភាពពិតប្រាកដ។

**ទម្រង់នៃពាក្យសុំ** ក្រមនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់ថា ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ត្រូវតែធ្វើឡើងដោយមានទម្រង់ណាមួយជាក់លាក់នោះទេ។

ចំពោះវិធានផ្ទៃក្នុងនៃ អ.វ.ត.ក បានចែងជាក់លាក់ និងកំណត់ពីទម្រង់នៃការដាក់ពាក្យសុំ និងមានអង្គភាពដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់ជួយក្នុងការកំណត់ពីការសរសេរ និងការដាក់ពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំពោះមុខសហចៅក្រមស៊ើបអង្កេត។ យើងខ្ញុំសង្ឃឹមថា នៅថ្ងៃអនាគតតាមស្ថាប័នតុលាការខ្មែរ នឹងបង្កើតឱ្យមានអង្គភាពនេះផងដែរ។

---

[8] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៧៥

[9] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ១៣៧ កថាខណ្ឌទី ១

[10] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖ វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) មាត្រា ២៣ ស្ទួន៖ បណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និង ការទទួលយកនូវពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី (ឧបសម្ព័ន្ធទី ០៧)

**ឧទាហរណ៍៖** ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ឈ្មោះ ទុន សួន (TUN Soun), ឯកសារលេខ D22/258 ត្រង់លេខ ERN 00426759 ។ សៀវភៅរបស់លោក Ben Kiernan, ដែលមានចំណងជើងថារបប ប៉ុល ពត (The Pol Pot Regime), ឯកសារលេខ D6.1.1.1106 ត្រង់លេខ ERN00104179 ។[11]

**នីតិវិធីនៃការដាក់ពាក្យសុំ** បុគ្គលគ្រប់រូបដែលបានប្រកាសខ្លួនជាជនរងគ្រោះ អាចសុំការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលា កាលណាការស៊ើបសួរត្រូវបានបើក។ ត្រង់ចំណុចនេះ វាមានភាពផ្ទុយគ្នាទៅនឹងការអនុវត្ត នៅ អ.វ.ត.ក ជនរងគ្រោះ ដែលមានបំណងចង់តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ យ៉ាងយូរ ១៥ថ្ងៃ បន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់ អំពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការ។ សហចៅក្រមស៊ើបអង្កេតអាចបដិសេធពាក្យសុំពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី រហូតដល់កាលបរិច្ឆេទចេញដីកាដំណោះស្រាយ ។[12]

ដើមបណ្ដឹងរដ្ឋប្បវេណី អាចធ្វើបានដោយការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ និង ការធ្វើដោយផ្ទាល់មាត់ក៏បាន។ ប្រសិនជាការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើតាមរយៈផ្ទាល់មាត់នោះ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុ [13] ដែលជាទូទៅចៅក្រមស៊ើបសួរឱ្យក្រឡាបញ្ជីកត់ត្រាចូលគ្នាក្នុងកំណត់ហេតុស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីតែមួយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹង អំពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនេះដល់ព្រះរាជអាជ្ញា និងជនត្រូវចោទផងដែរ ។[14]

កំឡុងពេលដែលទាមទារសំណងរដ្ឋប្បវេណី អាចមានឧបសគ្គ ឬហេតុការណ៍គតិយុត្តនានាដែលកើតមានឡើងដូចជា ៖

ការរលត់បណ្ដឹងអាជ្ញា [15] អាចកើតមានឡើងនៅកំឡុងនាពេលទាមទារសំណងពីជនត្រូវចោទ នៅពេលនីតិវិធីកំពុងតែដំណើរការរឿងព្រហ្មទណ្ឌ។ វាមានសំណួរគតិយុត្តចោទឡើងថា តើដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបាត់បង់សិទ្ធិទទួលបានសំណងរបស់ខ្លួនដែរ ឬទេ ។

---

[11] ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ឈ្មោះ ទុន សួន (TUN Soun), ឯកសារលេខ D22/258 ត្រង់លេខ ERN 00426759។ សៀវភៅរបស់លោក Ben Kiernan, ដែលមានចំណងជើងថា របប ប៉ុល ពត (The Pol Pot Regime),ឯកសារលេខ D6.1.1.1106 ត្រង់លេខ ERN00104179 (ឧបសម្ព័ន្ធទី ០៧)

[12] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ១៣៧ កថាខណ្ឌទី១

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ១៣៧ កថាខណ្ឌទី៣

[14] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ១៣៧ កថាខណ្ឌទី៥

[15] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា៧, មាត្រា៨

ជាការពិត ទោះបីជាការអនុវត្តសិទ្ធិដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណី ត្រូវបានអនុវត្តដោយជនរងគ្រោះក៏ពិតមែន ក៏ប៉ុន្តែសិទ្ធិនេះអាចត្រូវបានបន្តដោយសិទ្ធិវ័ន្តរបស់ជនរងគ្រោះបាន ករណីដែលអ្នកដាក់ពាក្យបណ្ដឹងរដ្ឋប្បវេណីបានទទួលមរណភាពក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌ ។ ជារួមទៅថ្វីត្បិតតែបណ្ដឹងអាជ្ញាត្រូវរលត់ តុលាការព្រហ្មទណ្ឌនៅតែមានសមត្ថកិច្ចដដែល រីឯជនរងគ្រោះនៅតែអាចទាមទារសំណងបានធម្មតា ។[16]

ករណី អ.វ.ត.ក ក្នុងសំណុំរឿង០០១ នៃ អ.វ.ត.ក ធ្លាប់បានធ្វើការសម្រេចពីលក្ខខណ្ឌមួយចំនួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានបន្តដោយសិទ្ធិវ័ន្តរបស់អ្នកដាក់ពាក្យបណ្ដឹង ជាដើមបណ្ដឹងរដ្ឋប្បវេណីដែលទទួលមរណភាព ។[17]

**ដំណាក់កាលជំនុំជម្រះ និងការសម្រេចសេចក្ដីរបស់ចៅក្រម** បន្ទាប់ពីបានរៀបរាប់ពី ដំណើរការនៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍រួចមក យើងខ្ញុំនឹងបកស្រាយបន្តពីដំណាក់កាលនៃការតាំងខ្លួនជាដើមបណ្ដឹង នៅក្នុងការជំនុំជម្រះវិញម្ដង ។

**ដំណើរការជំនុំជម្រះ** ដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវអន្តរាគមន៍ ត្រូវបានផ្ដល់សិទ្ធិជាចម្បងក្នុងការទាមទារសំណងដែលខ្លួនទទួលរងនូវការខូចខាត បើទោះបីជាដំណើរការនីតិវិធីស្ថិតនៅក្នុងការជំនុំជម្រះក៏ដោយ។ នាងខ្ញុំនឹងធ្វើការបកស្រាយ ពីនិតិវិធីនៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅពេលដែលនីតិវិធីកំពុងតែដំណើរការជំនុំជម្រះក្ដីខាងក្រោម ៖

**កាលកំណត់រយៈពេលតាំងខ្លួន** ក្នុងពេលសវនាការ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវធ្វើតាមការប្រកាសប្ដឹងសាមញ្ញនៅចំពោះមុខក្រឡាបញ្ជី ដែលការប្រកាសប្ដឹងនេះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃសវនាការ ។ ជាទូទៅឃើញថា មានជនរងគ្រោះមួយចំនួនគាត់តែងតែធ្វើការទាមទារ និងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅមុខចៅក្រមជំនុំជម្រះ បន្ទាប់ពីចៅក្រមបានធ្វើការសាកសួរជនរងគ្រោះ និងធ្វើការពន្យល់គាត់នៅពេលដែលបើកការជំនុំជម្រះ ។

**របៀបនៃការតាំងខ្លួនមុខចៅក្រមជំនុំជម្រះ** យ៉ាងណាមិញ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចទទួលបានទេក្រោយពីសេចក្ដីសន្និដ្ឋានសុំរបស់ព្រះរាជអាជ្ញាលើអង្គសេចក្ដី ។ ជនរងគ្រោះដែលបានតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរួចហើយ នៅពេលស៊ើបសួរនោះមិនបាច់បំពេញទម្រង់ការនេះជាថ្មីទៀតទេនៅមុខតុលាការ (ចៅក្រមជំនុំជម្រះ) ។[18]

---

[16] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា១៦, មាត្រា២៤

[17] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក),សាលក្រម អ.វ.ត.ក៖ ករណីកាំង ហ្គេចអ៊ាវ ហៅឌុច ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ទំព័រ៣៦៦, សេចក្ដីសម្រេចលើពាក្យសុំទាក់ទងនឹងមរណភាព សួស សារិន

[18] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣១១

**ការវាយតម្លៃពីព្យសនកម្មចំពោះការទទួលបានសំណង** ជាការពិត ចំពោះការសម្រេចសេចក្តីក្នុងការប្រគល់សំណងទៅឱ្យភាគីដែលទាមទារនោះ វាមិនមែនជារឿងសាមញ្ញសម្រាប់ចៅក្រមនោះទេ។ ដូច្នេះចៅក្រមត្រូវតែពិចារណាប្រកបដោយវិចារណញ្ញាណខ្ពស់ និងប្រកបដោយវិជ្ជាជីវៈក្នុងការកំណត់ពីសំណង ។

**ការប្រកាសពីពិរុទ្ធភាព** ជាទូទៅ តុលាការព្រហ្មទណ្ឌនឹងអាចសម្រេចការជួសជុលព្យសនកម្មបាន លុះត្រាតែបានពិនិត្យជាមុនអំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយបានប្រកាសថា ជនជាប់ចោទត្រូវមានពិរុទ្ធភាពជាមុនសិន ។[19]

**ឧទាហរណ៍៖** តុលាការបានសម្រេចផ្តន្ទាទោស លើជនជាប់ចោទឈ្មោះ ហាហា(គេចខ្លួន) ភេទប្រុស អាយុ ៥៥ឆ្នាំ ដាក់ពន្ធនាគារ កំណត់រយៈពេល ១៣ឆ្នាំ គិតពីថ្ងៃចាប់ខ្លួន ពីបទ *មនុស្សឃាតដោយចេតនា* ។ តុលាការបង្គាប់ឱ្យឈ្មោះ សជ គ្មានប្រាក់សងត្រូវបានដាក់ទណ្ឌកម្ម និងត្រូវដាក់គុកបង្ខំរូបកាយ ដើម្បីបង្ខំទារប្រាក់ធនទណ្ឌ ។

**ឧទាហរណ៍៖** សាលក្រមព្រហ្មទណ្ឌ លើសំណុំរឿង *លួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ* ប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ ០៦ខែ និងបង្គាប់ឱ្យជនជាប់ចោទឈ្មោះ ថថ សងជំងឺចិត្តចំនួន ២.០០០.០០០ (ពីរលាន)រៀល ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ញញ ។ ការទាមទារលើសពីនេះបដិសេធចោល ។

ប្រសិនបើជាក្រឡេកមកមើល វិធានផ្ទៃក្នុងរបស់អ.វ.ត.ក ឃើញថា៖ អ.វ.ត.ក សម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី នៅក្នុងសាលក្រម។ អ.វ.ត.ក មិនត្រូវសម្រេចអំពីបណ្តឹងរដ្ឋប្បវេណីដែលផ្ទុយទៅនឹងសាលក្រមសម្រេចអំពីបណ្តឹងអាជ្ញានៅក្នុងរឿងក្តីតែមួយឡើយ ។

ក្រៅពីនេះទាំងតុលាការជាតិ និងតុលាការអ.វ.ត.ក អាចបន្តការសម្រេចអំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី នៅក្នុងសវនាការដោយឡែកមួយទៀតបាន ដែលអាចធ្វើបាននៅចំពោះមុខសាលាជម្រះក្តីរដ្ឋប្បវេណី ប៉ុន្តែករណីនេះបណ្តឹងរដ្ឋប្បវេណីអាចត្រូវព្យួរសិន ពេលមិនទាន់មានសេចក្តីសម្រេចជាស្ថាពរមួយ ត្រូវបានប្រកាសលើបណ្តឹងអាជ្ញា ។[20]

**ការសម្រេចឱ្យរួចខ្លួន** ចៅក្រមជំនុំជម្រះ ពុំចងកាតព្វកិច្ចទាមទារ ឱ្យត្រូវតែគោរពតាមលិខិតចោទប្រកាន់នោះទេ ។ ដូច្នេះមានករណីខ្លះបទល្មើសមួយចំនួន មិនត្រូវបានរកឃើញពិរុទ្ធភាព ឬមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដែលតុលាការជំនុំជម្រះអាចឱ្យរួចខ្លួនបាន ។

**កំណត់សម្គាល់**

[19] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា២៣

[20] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា២២

**មានសំណួរគតិយុត្តចោទសួរថា** ប្រសិនជានៅពេលមានហេតុការណ៍ខាងលើតើសិទ្ធិទាមទារសំណងរបស់ដើមរដ្ឋប្បវេណី ត្រូវបានបាត់ដៃរឬទេ? ប្រសិនជាមិនបានបាត់បង់សិទ្ធិក្នុងការទាមទារសំណងនោះទេ តើតុលាការត្រូវអនុវត្តដូចម្តេច?

មុននឹងធ្វើការបកស្រាយទៅនឹងសំនួរគតិយុត្តខាងលើនេះ នាងខ្ញុំនឹងធ្វើការបកស្រាយពីវិធានដែលអនុវត្តនៅក្នុង អនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ក៏ដូចជាចែងនៅក្នុង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលបានចែង អំពីនីតិវិធីនៃការចោទប្រកាន់របស់ចៅក្រមៈ កាលណាតុលាការរកឃើញថាជនជាប់ចោទ គ្មានការទទួលខុសត្រូវព្រហ្មទណ្ឌទេ អ្នកដាក់ពាក្យសុំនឹងត្រូវអស់សិទ្ធិទាមទារសំណងក្នុងតុលាការរដ្ឋប្បវេណីផងដែរ ។[21]

ដូច្នេះជារួមទៅ យើងអាចធ្វើសេចក្តីសន្និដ្ឋានថា សាលាដំបូងក៏អនុវត្តដូចវិធានខាងលើនេះផងដែរ ។ ករណីបែបនេះ ដើមបណ្តឹងរដ្ឋប្បវេណីគប្បីតែធ្វើការដាក់ពាក្យបណ្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីវិញ ។

**របៀបនៃការសម្រេចសេចក្តី** ចៅក្រម ជាអ្នកដែលដើរតួនាទីយ៉ាងសំខាន់ ក្នុងការកំណត់ពីការជួសជុលព្យសនកម្ម រួមមានទាំងព្យសនកម្មផ្លូវកាយ, ព្យសនកម្មផ្លូវចិត្ត និងសម្ភារៈ ។ ព្យសនកម្មទាំងនេះអាចត្រូវបានសងទៅជនរងគ្រោះវិញ នូវទ្រព្យសម្បត្តិដែលបានបាត់បង់ ឬដោយការធ្វើឱ្យដូចសភាដើមឡើងវិញ នូវទ្រព្យសម្បត្តិដែលគេបានបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាតនោះ ។[22] ជាពិសេស ចៅក្រមត្រូវតែកំណត់ថា សំណងជម្ងឺចិត្តត្រូវតែមានលក្ខណៈធួនល្មមជាមួយនឹងព្យសនកម្មដែលទទួលរង ។[23]

**ការសម្រេចសេចក្តីដោយពឹងផ្អែកលើឯកសារ និងភស្តុតាង** ដើមបណ្តឹងរដ្ឋប្បវេណីត្រូវដាក់ឯកសារ និងភស្តុតាងឱ្យបានច្បាស់លាស់ ដើម្បីអាចឱ្យចៅក្រម យកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តី និងផ្តល់នូវសំណងឱ្យធួនល្មមចំពោះព្យសនកម្មដែលបានកើតមានឡើង។ ក្នុងករណីដែល ដើមបណ្តឹងរដ្ឋប្បវេណីមិនបានផ្តល់ឯកសារគ្រប់គ្រាន់ទេ ចៅក្រមនឹងពិបាកក្នុងការវិនិច្ឆ័យពីទំហំនៃព្យសនកម្មនោះ។

ក្នុងចំណោមព្យសនកម្មដែលមានដូចជា ព្យសនកម្មរូបរាងកាយ ព្យសនកម្មផ្លូវចិត្ត និងព្យសនកម្មផ្នែកសម្ភារៈ ឃើញថាព្យសនកម្មផ្លូវចិត្ត ជាប្រភេទព្យសនកម្ម ដែលចៅក្រមមានការ

[21] សេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាៈ សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក និងអន្តរជាតិ បោះពុម្ពផ្សាយលើកទី១ នៅខែមីនា ឆ្នាំ២០១៤ (ឧបសម្ព័ន្ធទី១៦)

[22] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា១៣, មាត្រា១៤

[23] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា១៤ កថាខណ្ឌ២

ពិបាកក្នុងការវាយតម្លៃយ៉ាងខ្លាំង ដោយសារតែវាជាផ្នែកមួយដែលមិនអាចមើលឃើញ ដោយភ្នែកទទេបាន។ ត្រង់ចំណុចនេះតាម រយៈបទពិសោធន៍របស់ចៅក្រមដែលបានអនុវត្តកន្លងមក ដើម្បីសម្រេចពីបញ្ហានេះ ចៅក្រមតែងតែអញ្ជើញអ្នកជំនាញ ឬអ្នកចិត្តសាស្ត្រមកចូលរួមធ្វើការវាយតម្លៃ។[24]

**ឧទាហរណ៍៖** ចៅក្រមសម្រេចសេចក្តីឱ្យឈ្មោះ ទៀវ ប៊ុនខេង ជាអ្នកទទួលខុសត្រូវ រដ្ឋប្បវេណីសងជូសឈ្មោះ គៀន ប៉ាវ នូវសោហ៊ុយបង់ខាងជម្ងឺចិត្ត ២០.០០០ រៀល ឱ្យទៅឈ្មោះ ហ៊ុយវ៉ា ។[25]

**ឧទាហរណ៍៖** សាលក្រមព្រហ្មទណ្ឌ លើសំណុំរឿង លួចមានស្ថានទម្ងន់ទោសដោយសារការកាប់គាស់ទម្លុះទម្លាយ៖ *ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឈឈ បានរៀបរាប់ពីការខូចខាតដែលមានដូចជា បាត់ម៉ូតូ១ ម៉ាស៊ីនចាក់ស៊ីឌី និងសម្ភារៈមួយចំនួនទៀត ដែលខ្លួនទាមទារសំណងចំនួន ៧០០ ដុល្លាសហរដ្ឋអាមេរិក ប៉ុន្តែជនរងគ្រោះមិនបានទាមទារសំណងជម្ងឺចិត្តនោះទេ។* តាមរយៈអង្គហេតុខាងលើនេះ ចៅក្រមសម្រេចសេចក្តីដើម្បីសងសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.០០០.០០០ លានរៀល ។

តាមរយៈការសាកសួរដោយផ្ទាល់ពីចៅក្រម បានបង្ហាញថា ការសម្រេចទាមទារចំពោះទំហំសំណង គឺអាស្រ័យទៅលើការពិនិត្យជាក់ស្តែងលើការខូចខាតដែលកើតមាន។ យ៉ាងណាមិញ ចៅក្រមពេលខ្លះក៏មិនបានពិនិត្យឱ្យបានស៊ីជម្រៅនោះទេ ដោយគ្រាន់តែផ្អែកតាមការយល់ឃើញ និងផ្តល់ឱ្យត្រឹមពាក់កណ្តាល ឬមួយភាគនៃចំនួនអតិបរមាដែលដើមបណ្តឹងបានទាមទារ។

**ការសម្រេចសេចក្តីដោយឆន្ទានុសិទ្ធិ** ការសម្រេចសេចក្តីរបស់ចៅក្រមអាចមានភាពខុសៗគ្នា ទៅតាមស្ថានភាពជាក់ស្តែងនៃសំណុំរឿង បើទោះបីជាជនរងគ្រោះ មានឯកសារ ឬ ភស្តុតាង ឬគ្មានឯកសារភស្តុតាងក្តី ក៏ចៅក្រមអាចប្រើប្រាស់អំណាចឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការវាយតម្លៃ និងកំណត់អំពីទំហំនៃសំណងសម្រាប់ ផ្តល់ទៅឱ្យជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។

ក្រៅពីនេះទៀត ករណីដែលដើមបណ្តឹងរដ្ឋប្បវេណី មិនបានកំណត់ចំនួនច្បាស់លាស់ពីសំណងដែលធ្វើការទាមទារនោះទេ ចៅក្រមនឹងមិនធ្វើការសម្រេចសេចក្តីពីការទាមទារនោះទេ ដោយទុកសិទ្ធិឱ្យប្តឹងទាមទារសំណងនៅតុលាការរដ្ឋប្បវេណី។

---

[24] បទសម្ភាសន៍ជាមួយចៅក្រម ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥

[25] ព្រឹត្តិប័ត្ររបស់សមាគមដើម្បីច្បាប់ខ្មែរ៖ វិធីសាស្ត្រគតិយុត្ត, បោះពុម្ពផ្សាយដោយ សមាគមដើម្បីច្បាប់ខ្មែរឆ្នាំ២០០៦ ត្រង់ទំព័រ៦៦ (ឧបសម្ព័ន្ធទី១៤)

**ឧទាហរណ៍៖** សាលក្រមព្រហ្មទណ្ឌ ក្នុងសំណុំរឿងលួច (ឆក់កាបូប) ដែលចៅក្រមបានសម្រេចសេចក្តីពីសំណាងថា៖ ទុកសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីប្តឹងទាមទារសំណងការខូចខាតនាពេលក្រោយ ។

ការសម្រេចសេចក្តី ដ៏ត្រឹមត្រូវ និងប្រកបដោយវិចារណញ្ញាណ របស់ចៅក្រមទោះបីមិនអាចស្តារឡើងវិញ នូវព្យសនកម្មទាំងមូលក្តី ក៏ការផ្តល់នូវសំណងទាំងនោះអាចជួយកាត់បន្ថយនូវការឈឺចាប់មួយចំនួនដល់ជនរងគ្រោះផងដែរ។ ហេតុដូច្នេះ គប្បីចៅក្រមពិចារណាឱ្យបានល្អិតល្អន់ ពីផលប៉ះពាល់ដែលកើតមានទាំងពេលបច្ចុប្បន្ន និងពេលខាងមុខរាល់ការសម្រេចសេចក្តី ។

**កថាខណ្ឌទី ២ ៖ អាជ្ញាយុកាលនៃបណ្តឹងរដ្ឋប្បវេណី**

បណ្តឹងរដ្ឋប្បវេណីត្រូវផុតអាជ្ញាយុកាលតាមវិធាននៃក្រមរដ្ឋប្បវេណី។ ប៉ុន្តែបណ្តឹងរដ្ឋប្បវេណីនេះមិនអាចធ្វើបានទៀតទេនៅមុខតុលាការព្រហ្មទណ្ឌ ក្រោយការផុតថិរវេលានៃអាជ្ញាយុកាលរបស់បណ្តឹងអាជ្ញា។[26]

[26] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា២៦

## ផ្នែកទី ៣ ៖ ភាគីនៃបណ្តឹងរដ្ឋប្បវេណី

ជាធម្មតា ភាគីក្នុងរឿងក្តីព្រហ្មទណ្ឌមានយ៉ាងហោចណាស់ពីរគឺ ម្ចាស់បណ្តឹងអាជ្ញា ដែលជាតំណាងអយ្យការ និងជនល្មើស។ ប៉ុន្តែក្នុងករណីខ្លះទៀត អាចមានបុគ្គលច្រើនជាងនេះទៅទៀត ដែលចូលរួមជាភាគីនៅក្នុងរឿងក្តីព្រហ្មទណ្ឌមាន ដូចជា៖ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដែលជាភាគីនៃបណ្តឹងរដ្ឋប្បណី។

### កថាខណ្ឌទី ១ ៖ ដើមបណ្តឹងរដ្ឋប្បវេណី

#### ១.១ ជនរងគ្រោះផ្ទាល់នៃបទល្មើស ឬតំណាងស្របច្បាប់

ជាគោលការណ៍ បណ្តឹងរដ្ឋប្បវេណីត្រូវអនុវត្តដោយជនរងគ្រោះនៃបទល្មើស ( មាត្រា ១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ) ។ ជាទូទៅមានតែអ្នករងគ្រោះផ្ទាល់ពីបទល្មើសតែប៉ុណ្ណោះ ដែលដឹងថាខ្លួនទទួលរងនូវការខូចខាតណាខ្លះ។ ម្យ៉ាងវិញទៀតមានតែអ្នករងគ្រោះនោះទេ ដែលដឹងពីហេតុការណ៍នៃបទល្មើស និងដឹងអត្តសញ្ញាណរបស់ជនល្មើសច្បាស់។ ដូច្នេះច្បាប់កំណត់យ៉ាងដូច្នេះ គឺសមហេតុផល និងត្រឹមត្រូវ។ ប៉ុន្តែក្នុងករណី ជនរងគ្រោះជាអនីតិជន ឬ ជាជនដែលស្ថិតនៅក្រោមរបបច្បាប់ការពារ ដែលសំដៅដល់ជនដែលមានវិបត្តិផ្នែកស្មារតីជាអាទិ៍ បណ្តឹងរដ្ឋប្បវេណី អាចត្រូវធ្វើឡើងក្នុងនាមជនរងគ្រោះបាន ដោយអ្នកតំណាងស្របច្បាប់។ ក្នុងអត្ថន័យនេះគឺថា ជនរងគ្រោះផ្ទាល់នៃបទល្មើស ជាអសមត្ថជន ដូចមានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩ សម្រាប់ការធ្វើសកម្មភាពបណ្តឹង គឺត្រូវធ្វើឡើងដោយបុគ្គលដែលគ្រប់គ្រង និងត្រួតពិនិត្យលើអសមត្ថជននោះ។

#### ១.២ សិទ្ធិវន្ត័របស់ជនរងគ្រោះ

ករណីជនរងគ្រោះបានទទួលមរណៈភាពដោយសារបទល្មើស ឬ ដោយកត្តាផ្សេងទៀត បណ្តឹងរដ្ឋប្បវេណី អាចត្រូវបានផ្តើមធ្វើ ឬ បន្តបានដោយសិទ្ធិវន្ត័។[27] ជាក់ស្តែង ជនរងគ្រោះ នៃបទល្មើសឃាតកម្ម ឬ មនុស្សឃាតដោយអចេតនា ជាអាទិ៍ គឺបានទទួលមរណៈភាព ឬ ក៏ករណីផ្សេងទៀតក្រោយរងគ្រោះពីបទល្មើស ជនរងគ្រោះអាចទទួលមរណៈភាពដោយសារហេតុការណ៍ផ្សេងៗទៀតដូចជា គ្រោះថ្នាក់ចរាចរណ៍ ឬ ជម្ងឺ ជាដើម ។ ក្នុងករណីនេះ ជនរងគ្រោះនៃបទល្មើសមិនអាចធ្វើបណ្តឹងរដ្ឋប្បវេណីបានទេ ដូច្នេះបណ្តឹងរដ្ឋប្បវេណីត្រូវផ្តើមធ្វើដោយសិទ្ធិវន្ត័របស់ជនរងគ្រោះ ឧទាហរណ៍ ដូចជាឪពុកម្តាយ ប្រពន្ធ ឬ កូន របស់ជនរងគ្រោះជាដើម ។ ករណីមួយទៀត

[27] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា១៦

ប្រសិនបើជនរងគ្រោះបានធ្វើបណ្តឹងរដ្ឋប្បវេណីហើយ ក្រោយមកជនរងគ្រោះបានទទួលមរណៈភាព បណ្តឹងរដ្ឋប្បវេណីនោះអាចបន្តបានដោយសិទ្ធិវន្តរបស់ជនរងគ្រោះផងដែរ ។

## ១.៣ សមាគមដែលបំពេញតាមលក្ខខណ្ឌច្បាប់

សមាគមប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រឆាំងនឹងកុមារ ដែលបានប្រកាសដោយត្រឹមត្រូវយ៉ាងតិចបំផុតតាំងពី ៣ឆ្នាំ មុនកាលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួនរួមមានការតស៊ូប្រឆាំងនឹងអំពើហិង្សាខាងផ្លូវភេទ ឬ អំពើហិង្សាក្នុងគ្រួសារ ឬ អំពើប្រឆាំងនឹងកុមារអាចប្រើប្រាស់សិទ្ធិទទួលស្គាល់ដល់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះប្រភេទបទល្មើសដូចជា៖

-ការបៀតបៀនដោយចេតនាដល់អាយុជីវិត

-ការបៀតបៀនដល់បូរណភាពនៃបុគ្គល

-និងការបៀតបៀនខាងផ្លូវភេទ[28]

សមាគមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដែលបានប្រកាសដោយត្រឹមត្រូវយ៉ាងតិចបំផុតតាំងពី ៣ឆ្នាំមុនកាលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួនរួមមាន ការតស៊ូប្រឆាំងនឹងការចាប់ពង្រត់ការជួញដូរមនុស្ស និងការអាជីវកម្មផ្លូវភេទអាចប្រើប្រាស់ សិទ្ធិដល់ដើមបណ្តឹងរដ្ឋប្បវេណីចំពោះបទល្មើសដែលបានបញ្ញត្តិដោយច្បាប់ ដែលពាក់ព័ន្ធនឹងការប្រឆាំង ការចាប់ពង្រត់ ការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ។[29]

សមាគមប្រយុទ្ធប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការរើសអើង ដែលបានប្រកាសដោយត្រឹមត្រូវយ៉ាងតិចបំផុតតាំងពី ៣ឆ្នាំ មុនកាលបរិច្ឆេទនៃបទល្មើស ហើយដែលកម្មវត្ថុនៃលក្ខន្តិកៈរបស់ខ្លួនរួមមានការតស៊ូ ប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការឧបត្ថម្ភដល់ជនរងគ្រោះនៃការរើសអើង ស្តីពីដើមកំណើតជាតិ ជាតិពន្ធុ ពូជសាសន៍ សាសនា អាចប្រើប្រាស់សិទ្ធិដល់ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះប្រភេទបទល្មើស ដូចបានកំណត់ខាងក្រោម កាលណាបទល្មើសនោះ ត្រូវបានប្រព្រឹត្ត ដោយមូលហេតុដើមកំណើតជាតិ នៃបុគ្គលណាម្នាក់ ឬ ដោយមូលហេតុថាបុគ្គលនោះជាសមាជិកពិតប្រាកដ ឬ ដោយស្មាននៃជាតិពន្ធុ ពូជសាសន៍ ឬ សាសនាណាជាកំណត់:

-ការរើសអើង

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា១៧

[29] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា១៨

-ការបៀតបៀនដោយចេតនា ដល់អាយុជីវិត ឬ ដល់បូរណភាពបុគ្គល

-ការបំផ្លាញ និងការធ្វើឱ្យខូចខាត ។[30]

ចំពោះសមាគម បណ្តឹងអាចត្រូវបានទទួលយកបាន លុះត្រាតែមានភស្តុតាងបញ្ជាក់ថា បានទទួលការយល់ព្រមពីជនរងគ្រោះ ឬ អ្នកតំណាងស្របច្បាប់។ ក្នុងករណីបៀតបៀនដល់អាយុជីវិត បណ្តឹងរបស់សមាគមអាចទទួលយកបាន លុះត្រាតែសមាគមបានបង្ហាញភស្តុតាងថា បានទទួលការយល់ព្រមអំពីសិទ្ធិពី សិទ្ធិវន្តនៃជនរងគ្រោះ ។

## កថាខណ្ឌទី២៖ អ្នកទទួលខុសត្រូវសំណងរដ្ឋប្បវេណី

### ២.១ ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត

បណ្តឹងរដ្ឋប្បវេណីអាចត្រូវធ្វើឡើងប្រឆាំងនឹងជនទាំងអស់ ដែលត្រូវជួសជុលព្យសនកម្មបណ្តាលមកពីបទល្មើសដូចជា ចារី។ ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់ ។[31] ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ឧទាហរណ៍ ៖ ឈ្មោះ ក. បានសម្លាប់ឈ្មោះ ខ. ដោយសារមានគំនុំក្នុងរបរកស៊ី ។ ដូច្នេះឈ្មោះ ក. គឺជាចារី ។

សហចារី ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងគ្នាប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់។[32] ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ឧទាហរណ៍ ៖ ឈ្មោះ ក. ឈ្មោះ ខ. និងឈ្មោះ គ. បានរួមគ្នាវាយឈ្មោះ ឃ. ដោយឈ្មោះ ក. ធាក់មួយជើង ឈ្មោះ ខ. វាយមួយដៃ និងឈ្មោះ គ. ច្រានឱ្យដួល។ ក្នុងសកម្មភាពបែបនេះ បានន័យថា ឈ្មោះ ក. ឈ្មោះ ខ. និងឈ្មោះ គ. គឺជាសហចារីនៃបទល្មើស ។

អ្នកផ្តើមគំនិត ត្រូវចាត់ជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែលៈ

១-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ តាមការណែនាំ ឬ ការបញ្ជា ។

២-បង្កឱ្យមានបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន ។

[30] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា១៩

[31] ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ មាត្រា ២៥

[32] ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ មាត្រា ២៦

អ្នកផ្តើមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវបានសម្រេច ឬ បានប៉ុនប៉ង។ អ្នកផ្តើមគំនិតនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវបានផ្តន្ទាទោសដូចគ្នានឹងចារីដែរ។[33]

ហេតុដូចនេះដើម្បីឱ្យអ្នកផ្តើមគំនិតមានទោសលុះត្រាតែ អំពើចម្បងមានទោស បទឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវបានសម្រេច ឬ ត្រូវបានប៉ុនប៉ង ។

**ឧទាហរណ៍ ៖** ឈ្មោះ ក. បានបញ្ជាឱ្យឈ្មោះ ខ. ទៅសម្លាប់ឈ្មោះ គ. ។ ប្រសិនបើឈ្មោះ ខ. ពុំបានទៅសម្លាប់ឈ្មោះ គ. ទេ មានន័យថា អំពើចម្បងនេះពុំមានទោសទេ ព្រោះពុំមានបទល្មើសកើតឡើង ។ ហេតុដូច្នេះ អ្នកផ្តើមគំនិតក៏ពុំមានទោសដែរ ។ ក្នុងករណីនេះ អំពើរបស់ឈ្មោះ ក. ពុំមែនជាការផ្តើមគំនិតដែលអាចត្រូវផ្តន្ទាទោសបានទេ តែអំពើនេះអាចត្រូវផ្តន្ទាទោសក្រោមឈ្មោះបទល្មើសមួយផ្សេងទៀត ពោលគឺ បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ដែលជាបទល្មើសដាច់ដោយឡែក ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី១លានរៀលទៅ៤លានរៀល តាមមាត្រា ៤៩៤ និងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ តែប្រាក់ពិន័យនេះជាប្រាក់ពិន័យចូលរដ្ឋប៉ុណ្ណោះ មិនមែនជាប្រាក់សំណងរដ្ឋប្បវេណីទេ ។

**ធាតុផ្សំសត្យានុម័តនៃការផ្តើមគំនិត** គឺចង់សំដៅលើការជម្រុញតាមការណែនាំ ឬ បញ្ជា ការបង្កដោយផ្តល់អំណោយ ដោយការសន្យា ឬ ការគំរាមកំហែង ការញុះញង់ ការលួងលោម ឬ ក៏ដោយការរំលោភអាជ្ញា ឬ អំណាចរបស់ខ្លួន ។

**ធាតុផ្សំអត្តនោម័តនៃការផ្តើមគំនិត** អ្នកផ្តើមគំនិតត្រូវមានបំណង ប្រព្រឹត្តអំពើផ្តើមគំនិត មានន័យថា អ្នកផ្តើមគំនិតបានដឹងថា អំពើរបស់ចារីជាបទល្មើសព្រហ្មទណ្ឌ ហើយខ្លួននៅតែមានចេតនាផ្តើមគំនិតចង់ឱ្យបទល្មើសនេះកើតបានទៀត ។

អ្នកសមគំនិត ត្រូវចាត់ទុកជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនា ដល់ការប៉ុនប៉ង ឬ ការសម្រេចបទឧក្រិដ្ឋ ឬ បទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬ ការឧត្ថម្ភរបស់ខ្លួន។ អ្នកសមគំនិតនឹងអាចត្រូវផ្តន្ទាទោសបានលុះត្រាតែបទឧក្រិដ្ឋ ឬ បទមជ្ឈិមត្រូវបានសម្រេច ឬ បានប៉ុនប៉ង។ អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ។[34] ក្នុងលក្ខណៈប្រហាក់ប្រហែលនឹងការផ្តើមគំនិតដែរ ការសមគំនិតត្រូវបំពេញលក្ខខណ្ឌបីយ៉ាងដើម្បីឱ្យមានទោសគឺ ៖

-អំពើចម្បងមានទោស

**-ធាតុផ្សំសត្យានុម័ត ៖** ការផ្តល់ជំនួយ ឬ ការឧបត្ថម្ភ ។

[33] ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ មាត្រា ២៨

[34] ក្រមព្រហ្មទណ្ឌ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ មាត្រា ២៩

**ឧទាហរណ៍ ៖** ឈ្មោះ ក. បានផ្តល់រថយន្តឱ្យចារីយកទៅប្រើប្រាស់ជាមធ្យោបាយក្នុងការប្រព្រឹត្តអំពើលួច ជាដើម ។

**-ធាតុផ្សំអត្តនោម័ត ៖** អ្នកសមគំនិតដឹងថា អំពើរបស់ចារីជាបទល្មើសហើយ ខ្លួននៅតែមានចេតនាផ្តល់ជំនួយ ឬ ឧបត្ថម្ភទៀត ។

**ឧទាហរណ៍ ៖** ឈ្មោះ ក. បានឱ្យរថយន្តឈ្មោះ ខ. ខ្ចីប្រើ ហើយ ឈ្មោះ ខ. បានយករថយន្តនេះទៅប្រើប្រាស់ ដើម្បីធ្វើជាមធ្យោបាយក្នុងការប្រព្រឹត្តអំពើលួច ។ ក្នុងករណីដែលឈ្មោះ ក. ពុំបានដឹងថា ឈ្មោះ ខ. នឹងយករថយន្តរបស់ខ្លួនទៅប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើសនោះ ឈ្មោះ ក. មិនអាចត្រូវផ្តន្ទាទោសពីការសមគំនិតបានឡើយ ដោយសារតែកង្វះធាតុផ្សំអត្តនោម័ត ។

### ២.២ អ្នកទទួលខុសត្រូវរដ្ឋប្បវេណីផ្សេងទៀត

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីផ្សេងទៀតសំដៅដល់បុគ្គលក្រៅពី ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ដែលអ្នកទាំងនោះរួមមាន៖

**ឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អ្នកអនីតិជន អ្នកគ្រប់គ្រង និងត្រួតពិនិត្យលើជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី** យោងតាមមាត្រា ៧៤៦ នៃក្រមរដ្ឋប្បវេណីបានបញ្ជាក់ថា ៖

១-បុគ្គលដែលមានករណីកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ឬ បុគ្គលដែលស្ថិតក្នុងស្ថានភាពដែលមិនអាចយល់ដឹង និង វិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬ មូលហេតុផ្សេងទៀត មានករណីកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើង ដោយអំពើបំពានរបស់បុគ្គលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននេះ ។

២-បុគ្គលដែលមានករណីកិច្ចដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើង ដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ ។

៣-បុគ្គលដែលមានករណីកិច្ចត្រួតពិនិត្យដែលទទួលខុសត្រូវក្នុងការសងការខូចខាត តាមបញ្ញត្តិនៃកថាខណ្ឌទី២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងការខូចខាតបានដោយបញ្ជាក់បង្ហាញថា ខ្លួនបានបំពេញករណីកិច្ចត្រួតពិនិត្យជាប្រក្រតី ។

**និយោជក** យោងតាមមាត្រា ៧៤៧ នៃក្រមរដ្ឋប្បវេណីបានចែងថា ៖

១-បុគ្គលដែលប្រើនិយោជិតដើម្បីអនុវត្តកិច្ចការ ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលនិយោជិតបានបង្កដល់អ្នកដទៃដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា នៅក្នុងការអនុវត្តកិច្ចការនោះ ។

២-បុគ្គលដែលស្ថិតក្នុងឋានៈត្រូវត្រួតពិនិត្យនិយោជិតជំនួសនិយោជក ត្រូវទទួលខុសត្រូវដូចគ្នានឹងនិយោជកដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះបានត្រួតពិនិត្យដោយត្រឹមត្រូវ ។

៣-និយោជក ឬ អ្នកត្រួតពិនិត្យជំនួស អាចទាមទារសំណងពីនិយោជិតបានដោយយោងទៅតាមកម្រិតនៃកំហុស របស់និយោជិតនោះ ។

**នីតិបុគ្គល** ជាទូទៅ គេរមែងគិតថា ការទទួលខុសត្រូវលើសំណងអាចមានសម្រាប់តែរូបវន្តបុគ្គលតែប៉ុណ្ណោះ ឬ និយាយមួយបែបទៀតថា មនុស្សទើបអាចទទួលខុសត្រូវលើរដ្ឋប្បវេណីបាន ក៏ប៉ុន្តែតាមការពិតក្រមរដ្ឋប្បវេណីក៏ទទួលស្គាល់ការទទួលខុសត្រូវរដ្ឋប្បវេណីរបស់នីតិបុគ្គលដែរ ។

តាមក្រមរដ្ឋប្បវេណី នៅត្រង់បញ្ញត្តិនៃមាត្រា ៧៤៨ បានបញ្ជាក់ថា ៖

១-នីតិបុគ្គលត្រូវទទួលខុសត្រូវក្នុងការសងការខូចខាត ដែលសមាជិកគណៈកម្មការនាយក ឬ អ្នកតំណាងឯទៀត បានបង្កដល់អ្នកដទៃទៀតដោយខុសច្បាប់ ដោយកំហុសចេតនា ឬ ដោយកំហុសអចេតនា ក្នុងការអនុវត្តភារកិច្ច ។

២-បើបានសងការខូចខាតតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ នីតិបុគ្គលអាចទាមទារសំណងពីអ្នកតំណាងដែលបានប្រព្រឹត្តអំពើបង្កការខូចខាតនោះ ។

## ផ្នែកទី៤៖ ការប្តឹងតវ៉ាចំពោះសេចក្តីសម្រេចពាក់ព័ន្ធនឹងបណ្តឹងរដ្ឋប្បវេណី

ការភាន់ច្រឡំនូវសេចក្តីសម្រេចរបស់តុលាការ គឺជារឿងមួយគួរឱ្យសោកស្តាយណាស់ ព្រោះថាធ្វើឱ្យមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិ និងពេលវេលា របស់ជនជាប់ចោទ។ ហេតុនេះ ផ្លូវតវ៉ាត្រូវបានបើកយ៉ាងទូលាយ ហើយមានច្រើនប្រភេទគឺ ៖ បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងសាទុក្ខ ។

### កថាខណ្ឌទី១៖ បណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ

ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចប្តឹងទាស់នឹងសាលក្រមដែលសម្រេចកំបាំងមុខខ្លួនបាន តាមមាត្រា ៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បណ្តឹងទាស់នេះត្រូវកំណត់ទៅលើសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលក្រមតែប៉ុណ្ណោះ។

បណ្តឹងទាស់ត្រូវធ្វើដោយពាក្យប្តឹងជាលាយលក្ខណ៍អក្សរ នៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ក្នុងករណីប្តឹងទាស់ដោយពិរុទ្ធជន ព្រះរាជអាជ្ញា អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ឬ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនដែលបានទទួលពាក្យប្តឹងទាស់របស់ពិរុទ្ធជន បញ្ជូនបណ្តឹងទាស់នោះភ្លាមទៅក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម (មាត្រា ៣៦៦) ។

ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី ក្នុងការដាក់ពាក្យប្តឹងទាស់ ប៉ុន្តែត្រូវមានលិខិតអនុញ្ញាតផងទើបបាន ។ ប៉ុន្តែពិរុទ្ធជនជាអនីតិជន អាចត្រូវតំណាងដោយឪពុកម្តាយ ឬ អ្នកអាណាព្យាបាល ដោយពុំចាំបាច់មានលិខិតប្រគល់សិទ្ធិទេ (មាត្រា ៣៦៦ កថាខណ្ឌទី២) ។ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏អាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់បានដែរ តែត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្តឹងទាស់ទើបបាន ។

បណ្តឹងទាស់ត្រូវធ្វើនៅក្នុងរយៈពេល ១៥ ថ្ងៃ ដោយផ្តើមគិតពី ៖

-ពីថ្ងៃជូនដំណឹងសាលក្រមកំបាំងមុខ កាលណាសាលក្រមត្រូវបានប្រគល់ជូនពិរុទ្ធជនដោយផ្ទាល់ដៃ ។

-ពីថ្ងៃដែលពិរុទ្ធជននោះបានដឹងយ៉ាងពិតប្រាកដអំពីសាលក្រម កាលណាសាលក្រមនេះមិនបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃទេ។ ពិរុទ្ធជនត្រូវចាត់ទុកថាបានដឹងយ៉ាងពិតប្រាកដពីសាលក្រម ក្នុងករណីដែល នីតិវិធីនៃការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ ស្របតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងក្រមនេះ (មាត្រា ៣៦៨ថ្មី និងមាត្រា ៣៧២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

ការឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការ ត្រូវអនុលោមតាមមាត្រា ៤៨២ ដល់មាត្រា ៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ តាមមាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដីកាឱ្យដំណឹងត្រូវធ្វើតាមគំនិតផ្ដើមរបស់ព្រះរាជអាជ្ញា របស់អគ្គព្រះរាជអាជ្ញា ឬ របស់ភាគី។ ដីកាឱ្យដំណឹង ត្រូវចុះនិទ្ទេសដូចតទៅ (មាត្រា៤៨៣) ៖

-ប្រភេទ និងការយោងនៃសេចក្ដីសម្រេចដែលត្រូវជូនដំណឹង

-អត្តសញ្ញាណ និងលំនៅឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្ដីសម្រេច

-កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកដែលធ្វើការជូនដំណឹង ។

ដីកាឱ្យដំណឹងបញ្ជាក់ប្រាប់អំពីផ្លូវតវ៉ាដែលអាចធ្វើបាន (ប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍) ប្រឆាំងនឹងសេចក្ដីសម្រេចដែលត្រូវបានជូនដំណឹង។ អ្នកជូនដំណឹងត្រូវភ្ជាប់នូវលិខិតចម្លងនៃសម្រេចដែលត្រូវជូនដំណឹង ទៅនឹងដីកាឱ្យដំណឹងផងដែរ (មាត្រា ៣៨៣ កថាខណ្ឌចុងក្រោយ) ។

ការជូនដំណឹងអាចធ្វើដោយ ៖

-ព្រះរាជអាជ្ញា (មាត្រា ៤៨៤)

-អាជ្ញាសាលា (មាត្រា ៤៨៥)

-ក្រឡាបញ្ជី

-អាជ្ញាធររដ្ឋបាល

-អាជ្ញាធរពន្ធនាគារ

-មន្ត្រីនគរបាលជាតិ ឬ អាវុធហត្ថ (មាត្រា ៤៨៩) ។

ការប្រគល់ការជូនដំណឹងធ្វើតាមមធ្យោបាយដូចតទៅ ៖

-ប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចឱ្យដល់ភាគីពាក់ព័ន្ធ។ ក្នុងករណីនេះ អ្នកប្រគល់ត្រូវចារលើសេចក្ដីសម្រេចដើមថា លិខិតចម្លងត្រូវបានប្រគល់ឱ្យភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ។ អ្នកប្រគល់ចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លង។ ភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្ដីសម្រេចដើ។ ក្នុងករណីដែលអ្នកប្រគល់ការជូនដំណឹងមិនមែនជាព្រះរាជអាជ្ញា សេចក្ដីសម្រេចដើមនេះត្រូវបង្វិលទៅ ព្រះរាជអាជ្ញាវិញជាបន្ទាន់ (មាត្រា ៤៨៦ មាត្រា ៤៨៩ កថាខណ្ឌទី៣) ។

ប្រសិនបើភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចឱ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន។ អ្នកប្រគល់ត្រូវចារលើសេចក្ដីសម្រេចដើមថា លិខិតចម្លងនៃសេចក្ដីសម្រេច ត្រូវបានប្រគល់ឱ្យដល់ដៃបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋាន និងចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ កាលបរិច្ឆេទនៃការប្រគល់លិខិត

ចម្លងនៃសេចក្តីសម្រេច។ បុគ្គលដែលទទួលលិខិតត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមដែលត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថា នឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធ ក្នុងរយៈពេលដ៏ខ្លីបំផុត។ ក្នុងករណីនេះ លិខិតចម្លងនៃសេចក្តីសម្រេចត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយមានចុះនិទ្ទេសដូចតទៅ៖ ឈ្មោះ និងអាសយដ្ឋាន របស់សាមីខ្លួនដែលត្រូវទទួលដីកានៅផ្នែកខាងមុខស្រោមសំបុត្រ ត្រារបស់អ្នកប្រគល់ដីកានៅផ្នែកខាងក្រោយស្រោមសំបុត្រ (មាត្រា ៤៩៤) ។

ក្នុងករណីដែលភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្តីសម្រេច ឬគ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ ឬគ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ ឬគ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធយល់ ព្រមទទួលសេចក្តីសម្រេចនោះទេ អ្នកប្រគល់ការឱ្យដំណឹង ត្រូវប្រគល់លិខិតនៃសេចក្តីសម្រេចទៅមេឃុំចៅសង្កាត់ ឬទៅជំឬទប់ ឬចៅសង្កាត់រងណាមួយ។ អ្នកប្រគល់ការឱ្យដំណឹងត្រូវ ចុះនិទ្ទេសនៅលើសេចក្តីសម្រេចដើម អំពីអត្តសញ្ញាណ និងឋានៈរបស់បុគ្គលដែលបានទទួលលិខិតចម្លងនៃសេចក្តីសម្រេច ព្រមទាំងកាលបរិច្ឆេទនៃការប្រគល។ បុគ្គលដែលទទួលលិខិតចម្លង ត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចដើម ដែលត្រូវបង្វិលជូនព្រះរាជអាជ្ញាវិញភ្លាម។ បុគ្គលដែលទទួលលិខិត សន្យាថានឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលខ្លីបំផុត។ ក្នុងករណីនេះលិខិតចម្លងនៃសេចក្តីសម្រេចត្រូវដាក់ក្នុងស្រោមសំបុត្របិទជិតដោយមានចុះនិទ្ទេសដូចតទៅ : ឈ្មោះ និងអាសយដ្ឋានរបស់សាមីខ្លួនដែលត្រូវទទួលដីកានៅផ្នែកខាងមុខស្រោមសំបុត្រ ត្រារបស់អ្នកប្រគល់ដីកានៅផ្នែកខាងក្រោយស្រោមសំបុត្រ (មាត្រា ៤៩៤) ។

ប្រសិនបើភាគីពាក់ព័ន្ធគ្មានលំនៅឋាន ឬ ទីសំណាក់ទេ ឬ ប្រសិនបើភាគីពាក់ព័ន្ធនេះរស់នៅក្រៅដែនដីជាតិសេចក្តីសម្រេចរបស់តុលាការក៏អាចជូនដំណឹងដល់សាមីខ្លួនបានដែរ។ ក្នុងករណីនេះ កាលបរិច្ឆេទនៃសេចក្តីសម្រេចតុលាការ ត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការជូនដំណឹង (មាត្រា ៤៩០) ។

ក្នុងករណីដែលការប្រគល់ការជូនដំណឹងត្រូវបានធ្វើតាមវិធីដូចដែលរៀបរាប់ខាងលើ គឺមានន័យថាការជូនដំណឹងត្រូវបានធ្វើត្រឹមត្រូវតាមនីតិវិធីរួចហើយ ។

នៅពេលដែលមានពាក្យបណ្តឹងទាស់ត្រឹមត្រូវ សំណុំរឿងត្រូវបានលើកយកមកជំនុំជម្រះដោយតុលាការដដែល (មាត្រា ៣៧១) ដោយភាគីទាំងអស់នឹងត្រូវបានកោះហៅ ។ សេចក្តីសម្រេចរបស់តុលាការអាចជា :

សាលក្រមលើកចោលបណ្តឹងទាស់ ដោយសារតែបណ្តឹងទាស់មិនអាចទទួលបាន។ បណ្តឹងទាស់មិនអាចទទួលបាន ដោយសារតែអ្នកដាក់ពាក្យប្តឹងទាស់ជាជនដែលពុំមានសិទ្ធិប្តឹងទាស់ ឬដោយសារតែការដាក់ពាក្យប្តឹងទាស់ធ្វើឡើងផុតរយៈពេលដែលច្បាប់កំណត់ ។

**ឧទាហរណ៍១**-សហព័ន្ធរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ពាក្យប្តឹងទាស់ ជំនួសឱ្យសហព័ទ្ធរបស់ខ្លួនដោយពុំមានលិខិតប្រគល់សិទ្ធិ ។

**ឧទាហរណ៍២**-ពិរុទ្ធជនដាក់ពាក្យប្តឹងទាស់ក្នុងរយៈពេលលើពី ១៥ ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹងពីសាលក្រមកំបាំងមុខ ។

សាលក្រមប្រកាសថាបណ្តឹងទាស់ទុកជាឯកសារឥតបានការ ហើយតម្កល់សាលក្រមដែលគេប្តឹងទាស់ទុកជាបានការដដែល ដោយមូលហេតុថា អ្នកប្តឹងទាស់មិនចូលបង្ហាញខ្លួននៅពេលសវនាការ ក្រោយពីបានទទួលការកោះហៅដោយត្រឹមត្រូវ (មាត្រា ៣៧១ កថាខណ្ឌទី ៣)។

សាលក្រមលើអង្គសេចក្តី ក្នុងករណីដែលអ្នកប្តឹងទាស់បង្ហាញខ្លួននៅពេលសវនាការ។ ក្នុងករណីនេះតុលាការអាចសម្រេចតម្កល់សេចក្តីសម្រេចមុន ឬកែប្រែ ឬបដិសេធសេចក្តីសម្រេច ហើយសម្រេចសេចក្តីសាជាថ្មីម្តងទៀតបាន ទៅតាមស្ថានភាពនៃរឿងនីមួយៗ។

សាលក្រមដែលសម្រេចលើបណ្តឹងទាស់អាចប្តឹងឧទ្ធរណ៍បាន ក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### កថាខណ្ឌទី២៖ បណ្តឹងឧទ្ធរណ៍ចំពោះសាលក្រម

អាចប្តឹងឧទ្ធរណ៍បាន :

-ពិរុទ្ធជន

-ដើមបណ្តឹងរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី។[35]

ទម្រង់នៃបណ្តឹងឧទ្ធរណ៍ដោយពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណី បណ្តឹងរបស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជីនៃតុលាការដែលបានប្រកាសសាលក្រម។ ពិរុទ្ធជនអាចត្រូវបានតំណាងដោយមេធាវី។ មេធាវីត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍។ ប៉ុន្តែ ពិរុទ្ធជនជាអនីតិជន អាចតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល។ ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍នេះ។ អ្នកទទួល

[35] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៧៥

ខុសត្រូវរដ្ឋប្បវេណីអាចតំណាងដោយ មេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍នេះ។ ក្រឡាបញ្ជីចុះបណ្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេសដែលរក្សាទុកនៅក្នុងបញ្ជីនៃតុលាការ។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយ ក្រឡាបញ្ជី និង អ្នកប្តឹងឧទ្ធរណ៍ ឬ អ្នកតំណាង។ លិខិតប្រគល់សិទ្ធិ ត្រូវភ្ជាប់នឹងលិខិតប្តឹងឧទ្ធរណ៍។[36] ការប្រកាសបណ្តឹងឧទ្ធរណ៍ដោយពិរុទ្ធជនដែលជាប់ឃុំ ពិរុទ្ធជនដែលជាប់ឃុំ អាចសំដែងឆន្ទៈរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍នៅមុខប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន។ ពិរុទ្ធជននេះបំពេញពាក្យប្តឹងឧទ្ធរណ៍ដែលត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខ។ ពាក្យប្តឹងឧទ្ធរណ៍ត្រូវចុះបញ្ជីដោយប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួននៅលើបញ្ជីពិសេស។ ពិរុទ្ធជនចុះហត្ថលេខានៅរឹមនៃបញ្ជីនេះ។ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ត្រូវបញ្ជូនពាក្យប្តឹងឧទ្ធរណ៍នៅក្នុងរយៈពេលដ៏ខ្លីបំផុត ទៅក្រឡាបញ្ជីនៃតុលាការដែលត្រូវចុះនិទ្ទេសអំពីពាក្យប្តឹងឧទ្ធរណ៍នេះ នៅលើបញ្ជីប្តឹងឧទ្ធរណ៍នៃតុលាការ។

**អ្នកប្តឹងឧទ្ធរណ៍ជាអនក្ខរជន** កាលណាអ្នកប្តឹងឧទ្ធរណ៍មិនចេះចុះហត្ថលេខា អ្នកប្តឹងឧទ្ធរណ៍នេះត្រូវផ្តិតម្រាមដៃ ។[37]

**ទម្រង់នៃបណ្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា** ការប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញា ត្រូវធ្វើតាមពាក្យប្តឹងនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។ ក្រឡាបញ្ជីចុះលិខិតប្តឹងឧទ្ធរណ៍នៅលើបញ្ជីពិសេស ដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍។ លិខិតប្តឹងឧទ្ធរណ៍ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអគ្គព្រះរាជអាជ្ញា។[38]

**ការបើកពិនិត្យមើលបញ្ជីបណ្តឹងឧទ្ធរណ៍** បញ្ជីបណ្តឹងឧទ្ធរណ៍នៃតុលាការជាប់ដំបូង និងសាលាឧទ្ធរណ៍អាចត្រូវបានភាគី និងមេធាវីពិនិត្យមើលបានដោយសេរី ។[39]

**រយៈពេលប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី** ការប្តឹងឧទ្ធរណ៍របស់ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវតែធ្វើក្នុងរយៈពេល ១ (មួយ) ខែ។ កាលណាសាលក្រមនោះជាសាលក្រមចំពោះមុខ រយៈពេលប្តឹងឧទ្ធរណ៍ផ្តើមគិតពីពេលប្រកាសសាលក្រម។ កាលណាសាលក្រមនោះជាសាលក្រមចាត់ទុកថា

[36] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៧៦
[37] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៧៨
[38] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៧៩
[39] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៨០

ចំពោះមុខ រយៈពេលប្ដឹងឧទ្ធរណ៍ផ្ដើមគិតពីពេលទទួលដំណឹងសាលក្រម ទោះបីការឱ្យដំណឹងនេះធ្វើតាមវិធីណាក៏ដោយ ។ [40]

**រយៈពេលបន្ថែមសម្រាប់ធ្វើបណ្ដឹងឧទ្ធរណ៍** បណ្ដឹងឧទ្ធរណ៍ឧប្បត្តិហេតុ ក្នុងករណីដែលភាគីណាមួយបានប្ដឹងឧទ្ធរណ៍នៅក្នុងរយៈពេលខាងលើនេះ ភាគីដទៃទៀតមានរយៈពេលបន្ថែម ៧ (ប្រាំពីរ) ថ្ងៃ ដើម្បីធ្វើបណ្ដឹងឧទ្ធរណ៍ឧប្បត្តិហេតុ។ រយៈពេលបន្ថែមនេះផ្ដើមគិតពីការផុតរយៈពេលធម្មតា។[41]

**រយៈពេលធ្វើបណ្ដឹងឧទ្ធរណ៍ក្នុងករណីមានការឃុំខ្លួនរបស់ព្រះរាជអាជ្ញា និង ពិរុទ្ធជន** ក្នុងរឿងឃុំខ្លួន ការប្ដឹងឧទ្ធរណ៍ត្រូវធ្វើដោយព្រះរាជអាជ្ញានៅក្នុងរយៈពេល ៤៨ (សែសិបប្រាំបី) ម៉ោង និងដោយពិរុទ្ធជនក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ។ រយៈពេលនេះផ្ដើមគិតពីថ្ងៃដែលតុលាការសម្រេចពីការឃុំខ្លួន។[42]

**បណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមចាត់របៀប** កាលណាតុលាការចេញសាលក្រមចាត់របៀប បណ្ដឹងឧទ្ធរណ៍អាចត្រូវទទួលបានភ្លាមប្រសិនបើសាលក្រមនេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលក្រមចាត់របៀបនឹងអាចត្រូវដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបានលុះត្រាតែធ្វើព្រមគ្នាជាមួយសាលក្រមលើអង្គសេចក្ដី ។[43]

**ការបញ្ជូនសំណុំរឿងទៅសាលាឧទ្ធរណ៍** ក្នុងករណីមានបណ្ដឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃតុលាការជាន់ដំបូងរៀបចំសំណុំរឿងដើម្បីបញ្ជូនទៅសាលាឧទ្ធរណ៍។ ក្រឡាបញ្ជីត្រូវផ្ញើនៅក្នុងរយៈពេលដ៏ខ្លីបំផុតជូនទៅដល់ការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍នូវ :

-សំណុំរឿងនៃនីតិវិធី

-សេចក្ដីចម្លងនៃលិខិតប្ដឹងឧទ្ធរណ៍នីមួយៗដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម

-សេចក្ដីចម្លងនៃសាលក្រមដោយមានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ។

---

40 ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៨២

41 ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៨៣

42 ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៨៤

43 ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៨៥

ក្នុងករណីមានបណ្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការស្តីអំពីការឃុំខ្លួនជនជាប់ចោទ សំណុំរឿងត្រូវបញ្ជូនក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរគិតពីថ្ងៃប្តឹងឧទ្ធរណ៍ លើកលែងតែមានកាលៈទេសៈមិនអាចជំនះបានដែលត្រូវតែមានបញ្ជាក់នៅក្នុងលិខិតបញ្ជូន ។[44]

**ការកំណត់កាលបរិច្ឆេទនៃសវនាការ និងរយៈពេលជំនុំជម្រះ** នៅពេលសំណុំរឿងទៅដល់សាលាឧទ្ធរណ៍ ប្រធានសភាព្រហ្មទណ្ឌពិនិត្យផ្ទៀងផ្ទាត់មើលថា តើទម្រង់បែបបទនៃបណ្តឹងឧទ្ធរណ៍បានត្រឹមត្រូវឬទេ និងកំណត់កាលបរិច្ឆេទនៃសវនាការ។ សាលាឧទ្ធរណ៍ត្រូវសម្រេចនៅក្នុងរយៈពេលសមស្រប។ ក្នុងករណីប្តឹងឧទ្ធរណ៍អំពីសេចក្តីសម្រេចរបស់តុលាការជាន់ដំបូងស្តីពីការឃុំខ្លួនជនជាប់ចោទ សាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេលដ៏ខ្លីបំផុត និងយ៉ាងយូរបំផុតក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពីថ្ងៃទទួលសំណុំរឿង។[45]

**ការជូនដំណឹង និងដីកាកោះហៅឱ្យចូលមកក្នុងសវនាការ** ប្រធានសភាព្រហ្មទណ្ឌជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការ ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញាកោះហៅជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដូចដែលមានចែងនៅក្នុងមាតិកាទី២ ស្តីពីដីកាកោះហៅជនជាប់ចោទឱ្យចូលសវនាការ និងមាតិកាទី ៣ ស្តីពីដីកាកោះហៅជនក្រៅពីជនជាប់ចោទឱ្យចូលសវនាការនៃគន្ថីទី ៧ ស្តីពីដីកាកោះហៅ បញ្ជូនទៅជំនុំជម្រះផ្ទាល់ ដីកាកោះហៅ និងដីកាជូនដំណឹងនៃក្រមនេះ។[46]

**ការផ្ទេរជនជាប់ចោទដែលជាប់ឃុំ** ជនជាប់ចោទដែលជាប់ឃុំត្រូវតែផ្ទេរនៅក្នុងរយៈពេលយ៉ាងខ្លីបំផុត តាមបញ្ជារបស់អគ្គព្រះរាជអាជ្ញាឱ្យទៅនៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនដែលនៅជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍ ។[47]

**របាយការណ៍ឧទ្ធរណ៍** ប្រធានសភាព្រហ្មទណ្ឌចាត់តាំងចៅក្រមធ្វើរបាយការណ៍ម្នាក់។ ចៅក្រមធ្វើរបាយការណ៍នេះអាចជា ប្រធាន ឬ ជាចៅក្រមអម។ របាយការណ៍មានកម្មវត្ថុរៀបរាប់អំពីដំណើររឿង ហើយនិងធ្វើឱ្យដឹងអំពីសាលក្រមដែលជូនមកសាលាឧទ្ធរណ៍នេះ។ របាយការណ៍ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវដាក់ក្នុងសំណុំរឿង។ របាយការណ៍ត្រូវតែក្បោះក្បាយល្អមដើម្បីឱ្យតុលាការបានទទួលព័ត៌មានយ៉ាងពេញលេញ។[48]

[44] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៨៦
[45] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៨៧
[46] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៨៨
[47] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៨៩
[48] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩០

**ការបើកពិនិត្យមើលសំណុំរឿង និង ការប្រគល់សារណា** អគ្គព្រះរាជអាជ្ញា និង មេធាវីអាច ពិនិត្យមើលសំណុំរឿងបានរហូតដល់ពេលសវនាការ។ ភាគី និង មេធាវីអាចប្រគល់សារណាដល់ ក្រឡាបញ្ជី។ សារណាត្រូវចុះទិដ្ឋាការដោយក្រឡាបញ្ជី ដោយមានកាលបរិច្ឆេទផង និងត្រូវដាក់ បញ្ចូលក្នុងសំណុំរឿងភ្លាម។[49]

**សារណភាពនៃកិច្ចពិភាក្សាដេញដោល និង ភាពជាសម្ងាត់នៃការពិភាក្សាដេញដោល** ការ ពិភាក្សាដេញដោលប្រព្រឹត្តទៅនៅពេលសវនាការជាសាធារណៈ។ ប៉ុន្តែ ប្រសិនបើតុលាការយល់ ឃើញថា ភាពជាសាធារណៈនាំឱ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ដល់ទំនៀម ទម្លាប់ តុលាការអាចបង្គាប់ឱ្យ ធ្វើការពិភាក្សាដេញដោលជាសម្ងាត់ទាំងស្រុង ឬ មួយផ្នែកបាន តាម សេចក្តីសម្រេចដោយមានសំអាងហេតុ។ តុលាការសម្រេចតាមសាលដីកាមួយដាច់ដោយឡែក ពីសាលដីកាលើអង្គសេចក្តី ឬ តាមសេចក្តីសម្រេចពិសេសនៃសាលដីកាលើអង្គសេចក្តី។ សេចក្តី សម្រេចរបស់តុលាការដែលបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់មិនអាចតវ៉ាបានឡើយ ។[50]

**ការសួរចម្លើយជនជាប់ចោទ** ក្រោយពីអានរបាយការណ៍រួច ប្រធានសួរចម្លើយជនជាប់ចោ ទ។ អគ្គព្រះរាជអាជ្ញា មេធាវី និង ភាគីទាំងឡាយ អាចអនុញ្ញាតឱ្យលើកជាសំណួរចោទសួរជនជាប់ ចោទ។ គ្រប់ការលើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាកា។ ក្រៅពីសំណួរ របស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងៗទៀតត្រូវសួរតាមរយៈប្រធានសវនាការ។ ក្នុង ករណីមានការជំទាស់ ប្រធានសម្រេចដោយឥស្សរចិត្តថាតើសំណួរនោះត្រូវសួរ ឬ យ៉ាងណា។[51]

**ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អ្នកជំនាញសាក្សី** ក្រោយពេលសួរចម្លើយជនជាប់ចោទរួច ប្រធានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួល ខុសត្រូវរដ្ឋប្បវេណី តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ សាក្សី និងអ្នក ជំនាញនឹងត្រូវបានគេស្តាប់ចម្លើយលុះត្រាតែតុលាការបង្គាប់ឱ្យស្តាប់ចម្លើយជនទាំងនេះ។[52]

**លំដាប់លំដោយនៃការនិយាយ** អគ្គព្រះរាជអាជ្ញា និង មេធាវី ឡើងនិយាយតាមលំដាប់ លំដោយនៃការហៅឈ្មោះ។ នៅក្នុងគ្រប់ករណីទាំងអស់ ជនជាប់ចោទនិយាយក្រោយគេបំផុត។ មេធាវីរបស់ជនជាប់ចោទត្រូវបានអនុញ្ញាតឱ្យធ្វើការកត់សម្គាល់ជាបន្ថែមដោយសង្ខេប ។[53]

---

[49] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩១

[50] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩២

[51] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩៣

[52] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩៤

[53] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩៥

**ការពន្លាតដល់សាលាឧទ្ធរណ៍នូវវិធានដែលអនុវត្តចំពោះសាលាដំបូង** លើសពីនេះវិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូង ត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍។[54]

**អានុភាពផ្ទេរនៃបណ្តឹងឧទ្ធរណ៍** សំណុំរឿងត្រូវបានផ្ទេរជូនសាលាឧទ្ធរណ៍នៅក្នុងព្រំដែនដែលកំណត់ដោយលិខិតប្តឹងឧទ្ធរណ៍ និង តាមឋានៈរបស់អ្នកប្តឹងឧទ្ធរណ៍។[55]

**អានុភាពនៃបណ្តឹងឧទ្ធរណ៍លើការអនុវត្តសាលក្រម** នៅក្នុងរយៈពេលបណ្តឹងឧទ្ធរណ៍ ការអនុវត្តសាលក្រមត្រូវបង្អង់សិន។ ប៉ុន្តែ ជនជាប់ចោទដែលជាប់ឃុំដែលបានចូលបង្ហាញខ្លួន នៅមុខតុលាការជាន់ដំបូងត្រូវនៅក្នុងពន្ធនាគារនៅក្នុងរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងក្នុងករណីមានបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចខាងបទព្រហ្មទណ្ឌ នោះជនជាប់ចោទត្រូវនៅក្នុងពន្ធនាគាររហូតដល់សាលាឧទ្ធរណ៍សម្រេច។ ក្នុងករណីដែលតុលាការជាន់ដំបូងបានសម្រេចឱ្យរួចខ្លួន ឬ បានផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលតិចជាង ឬ ស្មើនឹងរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ព្រះរាជអាជ្ញាអាចយល់ព្រមដោះលែងជនជាប់ចោទឱ្យមានសេរីភាព មុនពេលផុតកំណត់នៃរយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍។ រយៈពេលសម្រាប់ប្តឹងឧទ្ធរណ៍របស់អគ្គព្រះរាជអាជ្ញាមិនមែនជាឧបសគ្គដល់ការអនុវត្តទោសទេ។[56]

**អានុភាពនៃបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ** សាលាឧទ្ធរណ៍កាលណាបានទទួលបណ្តឹងឧទ្ធរណ៍តែពីជនជាប់ចោទប៉ុណ្ណោះ មិនអាចដាក់ទម្ងន់ទោសជននោះទេ។ តុលាការអាចកែប្រែសាលក្រមបាននៅក្នុងន័យដែលអនុគ្រោះដល់ជននេះតែប៉ុណ្ណោះ។ សាលាឧទ្ធរណ៍មិនអាចបន្ថែមទោសបន្ថែមពីលើមូលទោសបានទេ។ សាលាឧទ្ធរណ៍អាចជំនួសឈ្មោះបទល្មើសដែលកំណត់ដោយតុលាការជាន់ដំបូង ដោយឈ្មោះបទល្មើសមួយទៀតបាន ប៉ុន្តែ មិនអាចដាក់ទម្ងន់ទោសលើជនជាប់ចោទនេះទេ។ ប្រសិនបើតុលាការជាន់ដំបូងភ្លេចប្រកាសទោសបន្ថែមណាមួយដែលដាច់ខាតត្រូវតែប្រកាសនោះ សាលាឧទ្ធរណ៍បដិសេធសាលក្រមហើយសម្រេចអំពីទោសជាថ្មីម្តងទៀត។ កាលណាបានទទួលបណ្តឹងតែពីជនជាប់ចោទប៉ុណ្ណោះ សាលាឧទ្ធរណ៍មិនអាចបន្ថែមចំនួនទឹកប្រាក់ សម្រាប់ជួសជុលការខូចខាតឱ្យដល់ដើមបណ្តឹងរដ្ឋប្បវេណីទេ ។[57]

**អានុភាពនៃបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ របស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី** បណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចធ្វើបាន

---

[54] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩៦

[55] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩៧

[56] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩៨

[57] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៣៩៩

តែលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីប៉ុណ្ណោះ ។ នៅមុខសាលាឧទ្ធរណ៍ដើមបណ្តឹងរដ្ឋប្បវេណី មិនអាចធ្វើពាក្យប្តឹងសុំថ្មីដែលមិនបានដាក់ជូនតុលាការពិនិត្យនោះទេ ។[58]

**កថាខណ្ឌទី៣៖ បណ្តឹងទាស់ចំពោះសាលដីការបស់សាលាឧទ្ធរណ៍ចេញដោយកំបាំងមុខ**

**ទម្រង់នៃបណ្តឹងទាស់** បណ្តឹងទាស់អាចធ្វើ :

-តាមពាក្យប្តឹងលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានសម្រេចចេញសាលដីកា ឬ

-តាមពាក្យប្តឹងជាលាយលក្ខណ៍អក្សរនៅចំពោះមុខអគ្គព្រះរាជអាជ្ញា អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ឬ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។

ពិរុទ្ធជនអាចត្រូវតំណាងដោយមេធាវី។ មេធាវីត្រូវតែមានលិខិតអនុញ្ញាតឱ្យធ្វើបណ្តឹងទាស់ ។ ប៉ុន្តែ ពិរុទ្ធជនជាអនីតិជនត្រូវតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល។ ក្នុងករណីនេះ អ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ។

កាលណា បានទទួលពាក្យប្តឹងទាស់ អគ្គព្រះរាជអាជ្ញា អង្គភាពនគរបាល និងកងរាជអាវុធហត្ថ ព្រមទាំងប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន បញ្ជូនសំណុំរឿងនោះភ្លាមទៅសាលាឧទ្ធរណ៍ដែលបានប្រកាសចេញសាលដីកា ។

កាលណាអ្នកប្តឹងទាស់មិនចេះចុះហត្ថលេខាទេ សាមីខ្លួនត្រូវផ្តិតម្រាមដៃ។[59]

**បញ្ជីនៃបណ្តឹងទាស់** ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍កាន់បញ្ជីបណ្តឹងទាស់។ គូភាគី និងមេធាវីអាចបើពិនិត្យមើលបានដោយសេរី ។[60]

**រយៈពេលនៃបណ្តឹងទាស់** បណ្តឹងទាស់ត្រូវធ្វើក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពី :

-ថ្ងៃឱ្យដំណឹងអំពីសាលដីកាកំបាំងមុខ កាលណាសាលដីកានេះ ត្រូវបានប្រគល់ឱ្យដល់ពិរុទ្ធជនដោយផ្ទាល់ដៃ ។

-ថ្ងៃដែលពិរុទ្ធជនបានដឹងយ៉ាងពិតប្រាកដអំពីសាលដីកា កាលណាសាលដីកានេះមិនបានប្រគល់ឱ្យពិរុទ្ធជនដោយផ្ទាល់ដៃទេ ។[61]

បណ្តឹងទាស់ដែលកម្រិតចំពោះសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី បណ្តឹងទាស់អាចកំណត់ទៅលើតែសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលដីកាបាន ។[62]

[58] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤០០
[59] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤១០
[60] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤១១
[61] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤១២

បណ្តឹងទាស់ចំពោះសេចក្តីសម្រេចផ្នែកព្រហ្មទណ្ឌ ឬ រដ្ឋប្បវេណីនៃសាលដីកា កាលណាបណ្តឹងទាស់ធ្វើប្រឆាំងនឹងសាលដីកាទាំងមូល សាលដីកានេះ ត្រូវទុកជាអសារបង់ ។ ការអនុវត្តនៃសាលដីកាត្រូវព្យួរ ។ ប៉ុន្តែ ដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព ។ សាលាឧទ្ធរណ៍មានសមត្ថកិច្ចដើម្បីសម្រេចពីការដោះលែងឱ្យមានសេរីភាពវិញ។ កាលណាបណ្តឹងទាស់ធ្វើប្រឆាំងនឹងសេចក្តីសម្រេចផ្នែករដ្ឋប្បវេណី នោះសេចក្តីសម្រេចត្រង់ផ្នែកនេះត្រូវទុកជាអសារបង់ ហើយការអនុវត្តត្រូវព្យួរ ។[63]

**សាលដីកាចេញតាមបណ្តឹងទាស់** រឿងត្រូវលើកមកជំនុំជម្រះនៅមុខសាលាឧទ្ធរណ៍ដដែ។ គូភាគីត្រូវបានកោះហៅតាមគំនិតផ្តើមរបស់អគ្គព្រះរាជអាជ្ញា។ ក្រោយពីសម្រេចលើភាពដែលអាចទទួលបាននៃបណ្តឹងទាស់ តុលាការសម្រេចជាថ្មីលើអង្គសេចក្តី។ ប្រសិនបើអ្នកប្តឹងទាស់ដែលបានកោះហៅយ៉ាងត្រឹមត្រូវហើយតែមិនចូលមកបង្ហាញខ្លួននៅពេលសវនាការ តុលាការប្រកាសថាបណ្តឹងទាស់ត្រូវទុកជាអសារឥតការ។ សាលដីកាដែលប្តឹងទាស់ មិនអាចត្រូវបានកែប្រែបានទេ។ សាលដីកានេះមានអានុភាពទាំងស្រុងចំពោះគូភាគី។ ប៉ុន្តែ ពិរុទ្ធជនអាចប្តឹងតវ៉ាទៅតុលាការកំពូលបាន។[64]

**បណ្តឹងទាស់ធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី** ដើមបណ្តឹងរដ្ឋប្បវេណីក៏អាចប្តឹងទាស់នឹងសាលដីកាកំបាងមុខខ្លួនបានដែរ។ បណ្តឹងទាស់នេះ កំណត់ទៅលើតែសេចក្តីសម្រេចផ្នែករដ្ឋប្បវេណីនៃសាលដីកាប៉ុណ្ណោះ។

បណ្តឹងទាស់ត្រូវធ្វើឡើងក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គិតពី ៖

-ថ្ងៃឱ្យដំណឹងពីសាលដីកាកំបាំងមុខ កាលណាសាលដីកានេះត្រូវបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃ

-ថ្ងៃដែលដើមបណ្តឹងរដ្ឋប្បវេណីបានដងយ៉ាងពិតប្រាកដ អំពីសាលដីកា កាលណាសាលដីកានេះមិនបានប្រគល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ដៃទេ ។

បណ្តឹងទាស់អាចធ្វើជាលាយលក្ខណ៍អក្សរនៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ដែលបានប្រកាសសាលដីកា ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវតំណាងដោយមេធាវី សហព័ទ្ធ ឬ ដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរដែលអនុញ្ញាតឱ្យប្តឹងទាស់ ។

---

[62] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៥១៣

[63] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៥១៤

[64] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៥១៥

បទបញ្ញត្តិនៃមាត្រានេះត្រូវយកទៅអនុវត្តលើបុគ្គលដែលសាលាឧទ្ធរណ៍ប្រកាសឱ្យទទួលខុសត្រូវរដ្ឋប្បវេណី ។[65]

**កថាខណ្ឌទី៤៖ បណ្តឹងសាទុក្ខ**

**បុគ្គលដែលអាចធ្វើបណ្តឹងសាទុក្ខ** បណ្តឹងសាទុក្ខអាចត្រូវធ្វើដោយ :

-ជនជាប់ចោទ ឬ ពិរុទ្ធជន

-បុគ្គលដែលត្រូវគេទាមទារក្នុងករណីនៃនីតិវិធីបត្យាប័ន

-ដើមបណ្តឹងរដ្ឋប្បវេណី

-អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

បណ្តឹងសាទុក្ខ ត្រូវពិនិត្យដោយសភាព្រហ្មទណ្ឌនៃតុលាការកំពូល ។[66]

**មូលហេតុនៃបណ្តឹងសាទុក្ខ** តុលាការកំពូលអាចបដិសេធសេចក្តីសម្រេចក្នុងករណីដូចតទៅ :

-សមាសភាពមិនស្របច្បាប់នៃតុលាការ

-អសមត្ថកិច្ចនៃតុលាការ

-ការរំលោភអំណាច

-ការបំពានច្បាប់ ឬ ការអនុវត្តខុសច្បាប់

-ការបំពាន ឬ ភ្លេចទម្រង់ការ ដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ

-ការមិនបានសម្រេចលើពាក្យប្តឹងសុំរបស់អយ្យការ ឬ ភាគី កាលណាពាក្យប្តឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់

-ការបំភ្លៃអង្គហេតុ

-គ្មានសំអាងហេតុ

-ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្តីសម្រេច ។[67]

**រយៈពេលដើម្បីធ្វើបណ្តឹងសាទុក្ខ** បណ្តឹងសាទុក្ខ ត្រូវធ្វើក្នុងរយៈពេលដូចតទៅ :

-១ (មួយ) ខែ ចំពោះសាលដីការបស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍

-១៥ (ដប់ប្រាំ) ថ្ងៃ ចំពោះសាលដីការបស់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍

[65] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤១៦

[66] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤១៨

[67] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤១៩

កាលណាសាលដីកាដែលប្តឹងសាទុក្ខនេះ ជាសាលដីកាចំពោះមុខ រយៈពេលត្រូវផ្តើមគិតពីការប្រកាសសាលដីកា ។

កាលណាសាលដីកាដែលប្តឹងសាទុក្ខ ជាសាលដីកាដែលចាត់ទុកថាចំពោះមុខ រយៈពេលត្រូវផ្តើមពីការឱ្យដំណឹង ។

កាលណាសាលដីកាសម្រេចដោយកំបាំងមុខ រយៈពេលត្រូវផ្តើមគិតពីការផុតរយៈពេលប្តឹងទាស់ ។[68]

**បណ្តឹងសាទុក្ខចំពោះសាលដីកាចាត់របៀប** កាលណាសាលាឧទ្ធរណ៍ចេញសាលដីកាចាត់របៀប បណ្តឹងសាទុក្ខ ត្រូវទទួលបានភ្លាមប្រសិនបើសាលដីកានេះបញ្ចប់នីតិវិធី។ ក្នុងករណីផ្ទុយពីនេះ សាលដីកាចាត់របៀបអាចដាក់ជូនតុលាការកំពូលពិនិត្យជាមួយគ្នានឹងសាលដីកាលើអង្គសេចក្តីតែប៉ុណ្ណោះ ។[69]

**ទម្រង់នៃការប្រកាសបណ្តឹងសាទុក្ខ** បណ្តឹងសាទុក្ខត្រូវធ្វើតាមពាក្យប្តឹង នៅការិយាល័យក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ ដែលបានចេញសេចក្តីសម្រេច។ ពាក្យប្តឹងនេះត្រូវចុះក្នុងបញ្ជីពិសេសដែលរក្សាទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការនេះ។

ជនជាប់ចោទ ពិរុទ្ធជន និង បុគ្គលដែលត្រូវគេទាមទារក្នុងក្របខ័ណ្ឌនីតិវិធីបធ្យាប័នអាចតំណាងដោយមេធាវី។ មេធាវីត្រូវមានលិខិតប្រគល់សិទ្ធិឱ្យប្តឹងសាទុក្ខ។ ប៉ុន្តែជនជាប់ចោទ ឬ ពិរុទ្ធជនជាអនីតិជនអាចត្រូវតំណាងដោយឪពុក ម្តាយ ឬ អ្នកអាណាព្យាបាល ។ ក្នុងករណីនេះអ្នកតំណាងមិនចាំបាច់មានលិខិតប្រគល់សិទ្ធិទេ ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬ ដោយញាតិលោហិតផ្ទាល់ ។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខ ។

អ្នកទទួលខុសត្រូវរដ្ឋប្បវេណីអាចតំណាងដោយមេធាវី សហព័ទ្ធ ឬ ដោយញាតិលោហិតផ្ទាល់។ អ្នកតំណាងត្រូវមានលិខិតប្រគល់សិទ្ធិឱ្យធ្វើបណ្តឹងសាទុក្ខ ។[70]

**ការចុះហត្ថលេខាលើបណ្តឹងសាទុក្ខ** បណ្តឹងសាទុក្ខត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងអ្នកប្តឹង ឬ តំណាង ។ កាលណាអ្នកប្តឹងមិនចេះចុះហត្ថលេខាទេ សាមីខ្លួន ឬ អ្នកតំណាងត្រូវផ្តិតស្រាមដៃ ។ លិខិតប្រគល់សិទ្ធិត្រូវតែភ្ជាប់ជាមួយនឹងពាក្យសុំប្តឹងសាទុក្ខ ។

[68] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២០

[69] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២១

[70] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២២

ប្រសិនបើខ្វះហត្ថលេខារបស់ក្រឡាបញ្ជី ឬ ខ្វះកាលបរិច្ឆេទ ពាក្យប្តឹងសាទុក្ខអាចទទួលបាន ប្រសិនបើគ្មានឃើញការបន្លំអ្វីទេ ។ ក្រឡាបញ្ជីត្រូវរងទោសពិន័យ ៥.០០០ (ប្រាំពាន់) រៀល ។ ប្រាក់ពិន័យនេះត្រូវប្រកាសដោយតុលាការកំពូលនៅក្នុងសាលដីការបស់ខ្លួន ។[71]

**ការបញ្ជូនសំណុំរឿងទៅតុលាការកំពូល** នៅក្នុងរយៈពេលដ៏ខ្លីបំផុតក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍រៀបចំសំណុំរឿង ហើយបញ្ជូនទៅក្រឡាបញ្ជីតុលាការកំពូល ។[72]

**ការចុះបញ្ជីនៃសំណុរឿងនៅតុលាការកំពូល** នៅពេលដែលសំណុំរឿងបានទៅដល់តុលាការកំពូល ក្រឡាបញ្ជីត្រូវចុះបញ្ជី ។[73]

**ការតាំងមេធាវី** ភាគីអាចតាំងមេធាវីបានចាប់តាំងពីពេលចុះសំណុំរឿង ហើយយ៉ាងយូរបំផុតរហូតដល់មុនថ្ងៃបើកសវនាការ ១(មួយ)ថ្ងៃ។ ភាគីត្រូវបញ្ជូនឈ្មោះមេធាវីខ្លួនជាលាយលក្ខណ៍អក្សរឱ្យដល់ក្រឡាបញ្ជីតុលាការកំពូល ។[74]

**រយៈពេលសម្រាប់សរសេរសារណា** ក្រឡាបញ្ជីតុលាការកំពូលឱ្យដំណឹងដល់គូភាគីអំពីការចុះបញ្ជីនៃសំណុំរឿង ។ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ ក្រោយការឱ្យដំណឹងនេះ ក្រឡាបញ្ជីឱ្យដំណឹងដល់អ្នកប្តឹងសាទុក្ខថាខ្លួនមានថិរវេលា ២០ (ម្ភៃ) ថ្ងៃ ដើម្បីផ្ញើជូនសភាព្រហ្មទណ្ឌតុលាការកំពូលនូវសារណាមួយដែលខ្លួនត្រូវរៀបរាប់អំពីមធ្យោបាយខាងច្បាប់ ។ ប្រសិនបើអ្នកប្តឹងសាទុក្ខបានតាំងមេធាវី និងបានបញ្ជូនឈ្មោះមេធាវីនេះទៅក្រឡាបញ្ជី ការជូនដំណឹងនេះក៏ត្រូវផ្ញើទៅមេធាវីផងដែរ ។

ប្រសិនបើអ្នកប្តឹងសាទុក្ខបានជូនសារណា ក្រឡាបញ្ជីឱ្យដំណឹងដល់ភាគីដទៃទៀត និងជាយថាហេតុដល់មេធាវីដែលមានសថេរវេលា ២០ (ម្ភៃ) ថ្ងៃ ដែរ ដើម្បីឆ្លើយតបទៅនឹងសារណារបស់អ្នកប្តឹងសាទុក្ខ ។[75]

**ការដាក់សំណុំរឿងជូនពិនិត្យ** សំណុំរឿងត្រូវដាក់ជូនមេធាវីពិនិត្យមើលតាមត្រូវការ និងធ្វើការចម្លង ដោយសាមីខ្លួនជាអ្នកចេញសោហ៊ុយ ។[76]

[71] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២៣
[72] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២៤
[73] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២៥
[74] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២៦
[75] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២៧
[76] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២៨

**ការពន្យាររយៈពេលនៃការសរសេរសារណា** កាលណារយៈពេល ២០ (ម្ភៃ) ថ្ងៃ នេះមិនគ្រប់គ្រាន់ទេ ភាគីអាចសុំទៅដល់ប្រធានសភាព្រហ្មទណ្ឌឱ្យពន្យាពេល ។ ការពន្យាពេលនេះមិនអាចលើសពី ១០ (ដប់) ថ្ងៃ ទេ ។[77]

**ការចាត់តាំងចៅក្រមរបាយការណ៍** លុះដល់ផុតរយៈពេលកំណត់ដើម្បីជូនសារណា ប្រធានចាត់តាំងចៅក្រមរបាយការណ៍ម្នាក់ និងបញ្ជូនសំណុំរឿងទៅចៅក្រមនេះ ដោយមានភ្ជាប់សារណាទៅជាមួយផង ។[78]

**ការសសេររបាយការណ៍** របាយការណ៍ជាលាយលក្ខណ៍អក្សរត្រូវមានរៀបរាប់អំពី :

-នីតិវិធី និង រឿងហេតុ

-ចំណុចច្បាប់ដែលភាគីបានលើក

-ដំណោះស្រាយដែលចៅក្រមរបាយការណ៍ស្នើសុំ ។

របាយការណ៍ត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។[79]

**ការបញ្ជូនសំណុំរឿងទៅអគ្គព្រះរាជអាជ្ញា និងសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ៖**

សំណុំរឿងដោយមានសារណា និងរបាយការណ៍ភ្ជាប់ជាមួយផង ត្រូវបញ្ជូនទៅអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល រៀបចំសេចក្ដីសន្និដ្ឋានសុំជាលាយលក្ខណ៍អក្សរដែលត្រូវបញ្ចូលទៅក្នុងសំណុំរឿង ។

សំណុំរឿងត្រូវបញ្ជូនត្រឡប់ទៅប្រធានសភាព្រហ្មទណ្ឌវិញ ។[80]

**ការជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការចំពោះភាគី** ប្រធានសភាព្រហ្មទណ្ឌកំណត់កាលបរិច្ឆេទនៃសវនាការ និង ជូនដំណឹងដោយផ្ទាល់មាត់ដល់អគ្គព្រះរាជអាជ្ញាអំពីកាលបរិច្ឆេទនៃសវនាការនេះ ។ អគ្គព្រះរាជអាជ្ញាឱ្យដំណឹងអំពីកាលបរិច្ឆេទនេះដល់ភាគី និង មេធាវី ។

ការឱ្យដំណឹងដល់ជនជាប់ចោទដែលជាប់ឃុំ ដល់ពិរុទ្ធជនដែលឃុំខ្លួន ឬ ដល់បុគ្គលដែលគេទាមទារនៅក្នុងរឿងបត្យាប័ន ត្រូវធ្វើឡើងតាមរបៀបដូចតទៅ :

-ដោយផ្ទាល់មាត់ ឬ

-តាមរយៈប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ។

---

[77] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤២៩

[78] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣០

[79] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣១

[80] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣២

ការឱ្យដំណឹងដល់ពិរុទ្ធជន ឬ ជនជាប់ចោទនៅក្រៅឃុំ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និង ដល់មេធាវី ត្រូវធ្វើដូចតទៅ :

-ដោយផ្ទាល់មាត់

-តាមផ្លូវរដ្ឋបាល ឬ

-តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ ។

កាលណាការឱ្យដំណឹងត្រូវធ្វើដោយផ្ទាល់មាត់ ក្រឡាបញ្ជីចុះនិទ្ទេសអំពីកាលបរិច្ឆេទនៃការឱ្យដំណឹងទៅលើសំណុំរឿង ។ ពិរុទ្ធជន ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬ មេធាវី ចុះហត្ថលេខារបស់ខ្លួន ។

នៅក្នុងករណីដទៃទៀត ការឱ្យដំណឹងត្រូវធ្វើដោយមានបង្កាន់ដៃបញ្ជាក់ថាបានទទួលសម្រាប់ទុកជាសម្គាល់ ។[81]

**សាធារណភាពនៃកិច្ចពិភាក្សាដេញដោល** ការពិភាក្សាដេញដោលត្រូវប្រព្រឹត្តនៅពេលសវនាការជាសាធារណៈ ។ ភាគីមិនត្រូវបានសភាព្រហ្មទណ្ឌនៃតុលាការកំពូលស្តាប់ចម្លើយទេ លើកលែងតែក្នុងករណីដែលប្រធានបង្គាប់ឱ្យចូលមកបង្ហាញខ្លួន ។

ចៅក្រមរបាយការណ៍ធ្វើសេចក្តីរាយការណ៍ ។ អគ្គព្រះរាជអាជ្ញាធ្វើសេចក្តីសន្និដ្ឋានសុំ ។ មេធាវីធ្វើសេចក្តីសន្និដ្ឋានការពារ ។

ក្រោយពេលពិភាក្សាដេញដោល សភាព្រហ្មទណ្ឌថយខ្លួនទៅពិភាក្សាសម្រេច និងតែងសាលដីការបស់ខ្លួន ។ សាលដីកាអាចត្រូវប្រកាសក្នុងថ្ងៃជាមួយនោះតែម្តង ឬ ក៏នៅពេលសវនាការលើកក្រោយដែលត្រូវកំណត់ដោយតុលាការ ។

នៅក្នុងគ្រប់ករណី តុលាការកំពូលមិនអាចពិភាក្សាសម្រេចលើរឿងណាមួយដោយគ្មានធ្វើការពិភាក្សាដេញដោលនៅពេលសវនាការ ។

គ្រប់ភាគីទាំងអស់អាចដាក់ជូនសារណា ឬ សារណាថ្មីទៀត រហូតដល់បិទការពិភាក្សាដេញដោល ។[82]

**អានុភាពបង្អង់នៃបណ្តឹងសាទុក្ខ** នៅក្នុងរយៈពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខនោះ ការអនុវត្តសាលដីការបស់សាលាឧទ្ធរណ៍ត្រូវបង្អង់សិន ។ បណ្តឹងសាទុក្ខមានអានុភាពព្យួរ ។ ការអនុវត្តសេចក្តីសម្រេចដែលត្រូវតវ៉ានេះ ត្រូវតែបង្អង់ក្នុងខណៈដែលតុលាការកំពូលមិនទាន់បានសម្រេច ។

[81] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣៣

[82] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣៤

ប៉ុន្តែ ការអនុវត្តដក់ពន្ធនាគារមិនត្រូវបង្អង់ទេ នៅក្នុងករណីដែលជនជាប់ចោទបានបង្ហាញខ្លួននៅមុខសាលាឧទ្ធរណ៍ក្នុងឋានៈជាជនជាប់ឃុំនោះ ។ ដីកាបង្គាប់ឱ្យចាប់ខ្លួននៅតែមានអានុភាព ។ ការឃុំខ្លួនបណ្ដោះអាសន្ននៅតែបន្តអនុវត្ត ។ បុគ្គលជាប់ឃុំនៅក្នុងក្របខ័ណ្ឌនីតិវិធីបត្យាប័ននៅតែជាប់ឃុំដដែល ។ ក្នុងករណីមានការសម្រេចឱ្យរួចខ្លួន ជនជាប់ចោទត្រូវបានដោះលែងឱ្យមានសេរីភាព ។[83]

**សេចក្ដីសម្រេចលើបញ្ហាគតិយុត្ត** តុលាការកំពូលត្រូវសម្រេចលើបញ្ហាច្បាប់ដែលលើកឡើងដោយអ្នកប្ដឹងសាទុក្ខ និង ដែលមានរៀបរាប់នៅក្នុងសារណា ។[84]

**ការបោះបង់ចោលបណ្ដឹងសាទុក្ខ** ជនជាប់ចោទ ពិរុទ្ធជន បុគ្គលដែលត្រូវគេទាមទារក្នុងរឿងបត្យាប័ន ដើមបណ្ដឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចបោះបង់ចោលបណ្ដឹងសាទុក្ខរបស់ខ្លួន។ ការបោះបង់ចោលនេះ ត្រូវពិនិត្យកត់ត្រាដោយប្រធានសភាព្រហ្មទណ្ឌនៃតុលាការកំពូល ។[85]

**រយៈពេលសម្រាប់សម្រេចសេចក្ដី** តុលាការកំពូលត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ខែ គិតពីពេលទទួលសំណុំរឿ លើកលែងតែមានកាលៈទេសៈដែលមិនអាចជំនះបាន ។[86]

**ជំពូកនៃសេចក្ដីសម្រេចរបស់តុលាការកំពូល** សភាព្រហ្មទណ្ឌនៃតុលាការកំពូលអាច :

-បដិសេធបណ្ដឹងសាទុក្ខទាំងស្រុង ឬ មួយផ្នែក

-បដិសេធសាលដីការបស់សាលាឧទ្ធរណ៍ដែលគេតវ៉ានេះចោលទាំងស្រុង ឬ មួយផ្នែក។ ប្រសិនបើបណ្ដឹងសាទុក្ខត្រូវបានបដិសេធ នោះសេចក្ដីសម្រេចដែលតវ៉ាមានអាជ្ញាអស់ជំនុំ ។ អ្នកប្ដឹងសាទុក្ខមិនត្រូវបានអនុញ្ញាតឱ្យប្ដឹងសាទុក្ខជាថ្មីម្ដងទៀត អំពីសាលដីកាដដែលនោះទេ ។ កាលណាតុលាការកំពូលបដិសេធសេចក្ដីសម្រេចដែលគេតវ៉ា តុលាការកំពូលបញ្ជូនរឿង និងគូភាគីនៅចំពោះមុខសាលាឧទ្ធរណ៍មួយផ្សេងទៀត ឬ នៅចំពោះមុខសាលាឧទ្ធរណ៍ដដែល ប៉ុន្តែមានសមាសភាពថ្មីផ្សេងពីសមាសភាពមុន ។[87]

[83] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣៥
[84] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣៦
[85] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣៧
[86] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣៨
[87] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៣៩

**ការបដិសេធដោយគ្មានបង្វិលសំណុំរឿង** កាលណាអំពើដែលចោទប្រកាន់មិនមែនជាបទល្មើសទេ តុលាការកំពូលប្រកាសបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ដោយគ្មានបង្វិលសំណុំរឿងទៅវិញឡើយ ។[88]

**ការបដិសេធដោយមានការបង្វិលសំណុំរឿង** កាលណាតុលាការកំពូលយល់ឃើញថា អំពើដែលចោទប្រកាន់នោះ ជាបទល្មើសផ្សេងអំពីបទល្មើសនៅក្នុងសេចក្ដីសម្រេចដែលគេតវ៉ា ប៉ុន្តែបទល្មើសនេះត្រូវផ្តន្ទាទោសដូចគ្នា តុលាការកំពូលដោយមិនចាំបាច់ប្រកាសបដិសេធ អាចកែប្រែប្រភេទគតិយុត្តនៃអង្គហេតុជាថ្មី ដោយរក្សាទោសដែលបានប្រកាសហើយ និងសេចក្ដីសម្រេចផ្នែករដ្ឋប្បវេណីនៅដដែល ។

កាលណាតុលាការកំពូលយល់ឃើញថា អំពើដែលចោទប្រកាន់នោះ ជាបទល្មើសផ្សេងពីបទល្មើសនៅក្នុងសេចក្ដីសម្រេចដែលគេតវ៉ា ហើយបទល្មើសនេះត្រូវផ្តន្ទាទោសផ្សេងនោះ តុលាការកំពូលត្រូវបដិសេធសាលដីកាសាលាឧទ្ធរណ៍ និងបង្គាប់ឱ្យបញ្ជូនរឿងទៅសាលាជម្រះក្ដីមានសមត្ថកិច្ច ដើម្បីជំនុំជម្រះ ។[89]

**សាលដីកាជំនុំជម្រះពេញអង្គ** ប្រសិនបើតុលាការទទួលសំណុំរឿង បង្វិលមិនអនុលោមតាមសាលដីកាទីមួយ របស់តុលាការកំពូលទេ ហើយប្រសិនបើមធ្យោបាយដដែលត្រូវបានលើកយកមកធ្វើជាសំអាងសម្រាប់បណ្ដឹងសាទុក្ខលើកទីពីរ តុលាការកំពូលដែលជំនុំជម្រះជាសភាពេញអង្គនោះ សម្រេចសេចក្ដីលើអង្គហេតុ និងអង្គច្បាប់ ដោយចេញសាលដីកាស្ថាពរមេយ ។[90]

[88] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៤០
[89] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៤១
[90] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៤៤២

## ផ្នែកទី៥៖ ការបង្ខំដល់រូបកាយ

ការដែលបង្ខំដល់រូបកាយ ត្រូវអនុវត្តលើបុគ្គលដែលត្រូវផ្តន្ទាទោសដោយតុលាការព្រហ្មទណ្ឌ ហើយដែលមិនបង់ ប្រាក់ពិន័យ, ប្រាក់ពន្ធនៃនីតិវិធី, ប្រាក់សំណង និងជម្ងឺចិត្តដែលត្រូវបង់ឱ្យដើមបណ្តឹងរដ្ឋប្បវេណី។[91]

### កថាខណ្ឌទី១៖ មូលហេតុនៃការបង្ខំដល់រូបកាយ

ការដែលនាំឱ្យមានការបង្ខំដល់រូបកាយ មានដូចជា ការមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនៃនីតិវិធី និង តាមពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដូចខាងក្រោមនេះ។

### ១.១.ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនៃនីតិវិធី

ប្រសិនបើទណ្ឌិតមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនៃនីតិវិធី ដល់ព្រះរាជអាជ្ញានៃតុលាការអមសាលាដំបូង។ ព្រះរាជអាជ្ញាកំណត់រយៈពេលចុងក្រោយដល់ទណ្ឌិត ដើម្បីបង់ប្រាក់នោះ ហើយឱ្យដំណឹងថា ប្រសិនបើមិនបង់ទេនោះ សាមីខ្លួនអាចត្រូវបង្ខំដល់រូបកាយ។ រយៈពេលនេះមិនអាចតិចជាង ១០ (ដប់) ថ្ងៃ ទេ។ ការឱ្យដំណឹងត្រូវធ្វើ ដោយផ្ទាល់មាត់ ឬ តាមផ្លូវរដ្ឋបាល ឬ តាមរយៈអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថ។ ត្រូវតែមានធ្វើកំណត់ហេតុស្តីពីការឱ្យដំណឹងនេះ។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយទណ្ឌិត។ ប្រសិនបើទណ្ឌិតមិនចេះចុះហត្ថលេខាទេទណ្ឌិតត្រូវផ្តិតម្រាមដៃ។[92] លុះផុតរយៈពេលកំណត់ប្រសិនបើទណ្ឌិតមិនបានបង់ប្រាក់នោះទេ ព្រះរាជអាជ្ញាចេញបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន។ ព្រះរាជអាជ្ញាអាចបង្អង់សេចក្តីសម្រេចនេះបាន ដោយមូលហេតុមនុស្សធម៌ជាអាទិ៍ ដូចជាស្ថានភាពនៃសុខភាពរបស់ទណ្ឌិត។ បញ្ជាឱ្យបង្ខំនឹងឱ្យឃុំខ្លួនមានចុះនិទ្ទេសដូចតទៅ: អត្តសញ្ញាណនៃទណ្ឌិត, ប្រភេទ និងការយោងនៃទណ្ឌកម្ម, ការយោងនៃដីកាឱ្យដំណឹងដែលមានចែងនៅក្នុងមាត្រា ៥២៥ (ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនៃនីតិវិធី) នៃក្រមនីតិវិធីព្រហ្មទណ្ឌ, ចំនួនទឹកប្រាក់ដែលមិនបានបង់, ថេរវេលានៃការបង្ខំដល់រូបកាយ។ បញ្ជានេះត្រូវចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង។ ព្រះរាជអាជ្ញាសុំឱ្យកម្លាំងសាធារណៈចាប់ និងឃុំខ្លួនទណ្ឌិត។[93]

ថេរវេលានៃការបង្ខំដល់រូបកាយត្រូវកំណត់ដូចតទៅ៖

១០(ដប់)ថ្ងៃ កាលណាទឹកប្រាក់ដែលមិនបង់នោះមានចំនួនមិនលើសពី ២៥០០០០(ពីរសែនប្រាំម៉ឺន)រៀល។

---

[91] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៥២៣

[92] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៥២៥

[93] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៥២៦

២០(ម្ភៃ)ថ្ងៃ ប្រសិនបើទឹកប្រាក់នេះមានចំនួនពី ២៥០.០០១(ពីរសែនប្រាំម៉ឺនមួយ)រៀល ដល់ ៥០០.០០០(ប្រាំសែន)រៀល។

១(មួយ)ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនមិនពី ៥០០.០០១(ប្រាំសែមួយ)រៀល ដល់ ១.០០០.០០០(មួយលាន)រៀល។

២(ពីរ)ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនមិនពី ១.០០០.០០១(មួយលានមួយ)រៀល ដល់ ២.៥០០.០០០(ពីរលានប្រាំសែន)រៀល។

៣(បី)ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនមិនពី ២.៥០០.០០១(ពីរលានប្រាំសែនមួយ) រៀល ដល់ ៥.០០០.០០០(ប្រាំលាន)រៀល។

៦(ប្រាំមួយ)ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនមិនពី ៥.០០០.០០១(ប្រាំលានមួយ)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល។

១(មួយ)ឆ្នាំ ប្រសិនបើទឹកប្រាក់នេះមានចំនួនមិនពី ១០.០០០.០០១(ដប់លានមួយ)រៀល ដល់ ២០.៥០០.០០០(ម្ភៃលានប្រាំសែន)រៀល។

១៨(ដប់ប្រាំបី)ខែ ប្រសិនបើទឹកប្រាក់នេះមានចំនួនមិនពី ២០.៥០០.០០១(ម្ភលានប្រាំសែនមួយ)រៀល ដល់ ៥០.០០០.០០០(ហាសិបលាន)រៀល។

២(ពរ)ឆ្នា ប្រសិនបើទឹកប្រាក់នេះមានចំនួនមិនពី ៥០.០០០.០០០(ហាសិបលាន)រៀល ។

កាលណាការបង្ខំដល់រូបកាយធានាការប្រមូលឥណទេយ្យច្រើននោះថិរវេលានៃការបង្ខំនេះត្រូវកំណត់ដោយគិតគូរតាមចំនួនសរុបនៃទណ្ឌកម្ម។[94]

## ១.២. ការបង្ខំដល់រូបកាយតាមពាក្យប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

កាលណាដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលប្រាក់សំណង និងជម្ងឺចិត្តពីទណ្ឌិត ឬ ពីអ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ដើមបណ្តឹងរដ្ឋប្បវេណី អាចសុំដល់ព្រះរាជអាជ្ញាឱ្យធ្វើការបង្ខំដល់រូបកាយបាន។ ការបង្ខំដល់រូបកាយដើម្បីទារសំណង និងជម្ងឺចិត្ត អាចអនុវត្តបានតែនៅលើទណ្ឌិតប៉ុណ្ណោះ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវជូនភស្តុតាងថា ខ្លួនបានប្រើអស់មធ្យោបាយអនុវត្តដែលមានចែងក្នុងច្បាប់ដូចជាការរឹបអូសចលនវត្ថុ ឬ អចលនវត្ថុជាដើម។ ព្រះរាជអាជ្ញាអាចហៅដើមបណ្តឹងរដ្ឋប្បវេណីឱ្យធ្វើនីតិវិធីថ្មី ដើម្បីសាកល្បងទារប្រាក់សំណង និងជម្ងឺចិត្តនេះ។ ប្រសិនបើទណ្ឌិតមិនព្រមបង់ ការបង្ខំដល់រូបកាយត្រូវយកមកអនុវត្តនៅក្នុងលក្ខខណ្ឌដែលមានចែងនៅមាត្រា ៥២៣ (ការបង្ខំដល់រូបកាយក្នុងករណីមិនបង់ប្រាក់ពិន័យ ឬ ប្រាក់ពន្ធនៃនីតិវិធី) ដល់មាត្រា ៥៣២ ( ភាពនៅតែមិនរួចពីបំណុលដដែល) នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីមានការប្រេដែងគ្នារវាងប្រាក់

[94] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៥៣០

ពិន័យ ប្រាក់ពន្ធនៃនីតិវិធី និងប្រាក់សំណង និង ជម្ងឺចិត្ត នោះប្រាក់សំណង និងជម្ងឺចិត្ត ត្រូវទទួលសងមុនគេ។[95]

យោងតាមមាត្រា ៥២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការបង្ខំដល់រូបកាយមានលក្ខខណ្ឌដូចគ្នានឹងការជាប់ទោសពន្ធនាគារដែរ មានន័យថា ទណ្ឌិតនឹងត្រូវចាប់ខ្លួនយកទៅឃុំឃាំងនៅក្នុងពន្ធនាគារ ដូចករណីអនុវត្តទោសដាក់ពន្ធនាគារតាមអំណាចនៃសេចក្ដីសម្រេចរបស់តុលាការអញ្ចឹងដែរ ។

ជាពិសេស ការបង្ខំដល់រូបកាយមិនមែនជាមធ្យោបាយសម្រាប់ទូទាត់បំណុលទេ ហេតុដូច្នេះ ទោះបីជាក្នុងលក្ខខណ្ឌដែលទណ្ឌិតបានទទួលការបង្ខំដល់រូបកាយរួចហើយក៏ដោយ ក៏បំណុលនៅតែមានអត្ថិភាពជាដរាប ។ ក៏ប៉ុន្តែ ទណ្ឌិតមិនអាចត្រូវទទួលរងនូវការបង្ខំដល់រូបកាយចំពោះបំណុលដដែលនេះសាជាថ្មីម្ដងទៀតបានទេ ។

## កថាខណ្ឌទី២៖ ការរួចខ្លួនពីការបង្ខំដល់រូបកាយ

### ១. ការរួចខ្លួនពីការបង្ខំដល់រូបកាយ

ការបង្ខំដល់រូបកាយ មិនអាចធ្វើទៅលើទណ្ឌិតជាអនីតិជននៅពេលប្រព្រឹត្តបទល្មើសទៅលើស្ត្រីដែលមានអាយុចាប់ពី ៦៥ (ហុកសិបប្រាំ) ឆ្នាំ ឡើងទៅ និងទៅលើបុរសអាយុចាប់ពី ៧០ (ចិតសិប) ឆ្នាំ ឡើងទៅបានឡើយ។ ការបង្ខំដល់រូបកាយមិនអាចធ្វើបានព្រមជាមួយគ្នាទៅលើប្ដី និងប្រពន្ធបានទេ ទោះបីជាការបង្ខំនេះធ្វើឡើង ដើម្បីប្រមូលធនទណ្ឌផ្សេងគ្នាក៏ដោយ។

### ២. ការដោះលែងឱ្យមានសេរីភាពវិញ

ក្នុងករណីលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួននោះ ទណ្ឌិតត្រូវដោះលែងឱ្យមានសេរីភាពវិញ។ ប្រសិនបើពេលចាប់ខ្លួន ឃុំខ្លួន ឬ ក្រោយមកទណ្ឌិតតវ៉ាអំពីសេចក្ដីសម្រេចរបស់ព្រះរាជអាជ្ញា ទណ្ឌិតត្រូវបានគេនាំខ្លួនទៅជូនប្រធានតុលាការ។ ប្រធានតុលាការពិនិត្យមើលនីត្យានុកូលភាពនៃបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន។ ក្នុងករណីមានការបំពានច្បាប់ ប្រធានតុលាការលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួននេះ។ ប្រធានតុលាការសម្រេចតាមដីកាដោយមានសំអាងហេតុ។ សេចក្ដីសម្រេចរបស់ប្រធានតុលាការជាន់ដំបូង អាចត្រូវតវ៉ាទៅប្រធានសាលាឧទ្ធរណ៍បានក្នុងរយៈពេល ២ (ពីរ) ថ្ងៃ។ បណ្ដឹងតវ៉ានេះអាចធ្វើបានដោយអគ្គព្រះរាជអាជ្ញា ព្រះរាជអាជ្ញាអមសាលាដំបូង ឬ ទណ្ឌិត។ កាលណាប្រធានតុលាការជាន់ដំបូងលុបចោលបញ្ជាឱ្យបង្ខំ និងឱ្យឃុំខ្លួន សេចក្ដីសម្រេចនេះ គ្មានអានុភាពអនុវត្តទេ ក្នុងរយៈពេល ២ (ពីរ) ថ្ងៃ ដូចមានចែងនៅកថាខណ្ឌទី៤ នៃមាត្រានេះ។

[95] ក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ ២០០៧ មាត្រា ៥៣៣

ប្រសិនបើមានការតវ៉ា សេចក្តីសម្រេចនេះគ្មានអានុភាពអនុវត្តរហូតដល់មានដីការបស់ប្រធានសាលាឧទ្ធរណ៍។ ប្រធានសាលាឧទ្ធរណ៍សម្រេចតាមដីកាមានសំអាងហេតុ និងមិនអាចតវ៉ាបាន។

# សេចក្តីសន្និដ្ឋាន

"លក្ខណៈពិសេសរបស់បណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីព្រហ្មទណ្ឌ" គឺជាប្រធានបទថ្មី និងបានឆ្លុះបញ្ចាំងឱ្យឃើញពីដំណើរការក្នុងការទាមទារសំណង ពីអំពើព្យសនកម្មនានា ។ ជាពិសេស ការទាមទារសំណងនេះគឺផ្តែកសំខាន់ទៅលើការទាមទារសំណងរដ្ឋប្បវេណី នៅក្នុងរឿងក្តីព្រហ្មទណ្ឌ និងបង្ហាញអំពីបណ្តឹងរដ្ឋប្បវេណី គឺអាចទាមទារទៅលើផលប្រយោជន៍រដ្ឋប្បវេណីតែប៉ុណ្ណោះ ។

យើងខ្ញុំសង្ឃឹមជឿជាក់ថា សារណាមួយនេះ គឺជាមូលដ្ឋានគ្រឹះជួយឱ្យអ្នកអានយល់ដឹងពីភាពខុសប្លែកគ្នា រវាងបទបញ្ញត្តិក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងទម្លាប់អនុវត្តនៅសាលាដំបូងនានា ក៏ដូចជាការអនុវត្តនៅ អ.វ.ត.ក ។ ក្រៅពីនេះ ប្រធានបទនេះ ជួយជម្រុញឱ្យលោកអ្នកយល់ច្បាស់ ពីលក្ខខណ្ឌនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងដំណាក់កាលនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ។

យើងខ្ញុំកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង្ហាញពីព្យសនកម្ម ទាំងផ្នែកសម្ភារៈ ព្យសនកម្មរូបរាងកាយ និងព្យសនកម្មផ្លូវចិត្ត ឱ្យបានច្បាស់លាស់នៅឡើយនោះទេ ។ ត្រង់ចំណុចនេះ វាជាការបង្ហាញឱ្យឃើញពីកង្វះការយល់ដឹងរបស់ជនរងគ្រោះ និងខ្វះការផ្សព្វផ្សាយប្រព័ន្ធច្បាប់ ឱ្យបានទូលំទូលាយ ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមជឿជាក់ថា ប្រសារណាមួយនេះនឹងក្លាយជាប្រយោជន៍មួយសម្រាប់ជួយឱ្យលោកអ្នកបានយល់កាន់តែច្បាស់អំពីការដាក់បណ្តឹងរដ្ឋប្បវេណី នៅក្នុងរឿងក្តីព្រហ្មទណ្ឌ ។

# អនុសាសន៍

ក្នុងនាមនាងខ្ញុំជាអ្នកស្រាវជ្រាវ នាងខ្ញុំមានអនុសាសន៍ដូចតទៅ៖

១.ជនរងគ្រោះ និង ដើមបណ្ដឹងរដ្ឋប្បវេណី៖ រាល់ការដាក់ភស្តុតាង គប្បីដាក់ឯកសារឱ្យបាន ច្បាស់លាស់ និង បង្ហាញពីព្យសនកម្មទាំងផ្លូវកាយ ផ្លូវចិត្ត និងព្យសនកម្មសម្ភារៈ ។

២.ដំណាក់កាលនៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី៖ នៅដំណាក់កាលនីមួយៗនៃការទាមទារ សំណង ត្រូវគោរពឱ្យបានត្រឹមត្រូវតាមរយៈពេលកំណត់ ដើម្បីជៀសវាងការថ្លោះសិទ្ធិទាមទារ សំណង ជាមួយនឹងតុលាការព្រហ្មទណ្ឌ ហើយត្រូវខាតពេលដាក់ពាក្យបណ្ដឹងទៅតុលាការរដ្ឋ ប្បវេណី ។

៣.ការសម្រេចសេចក្ដីរបស់ចៅក្រម៖ ចៅក្រមត្រូវតែកំណត់ឱ្យបានជាក់លាក់ និង ច្បាស់លាស់ពី ការកំណត់ទំហំព្យសនកម្ម ដែលត្រូវសងសំណងឱ្យបានត្រឹមត្រូវ ។

ជាកិច្ចចុងក្រោយ នាងខ្ញុំសង្ឃឹមថា ការសរសេរប្រធានបទនេះ ជាប្រភព័ត៌មានថ្មី និង ជា ដំណើរការមួយដែលជាការដាស់តឿន ដល់ស្ថាប័នអនុវត្តច្បាប់ទាំងអស់ត្រូវតែយកចិត្តទុកដាក់ និង ពង្រឹងឱ្យដំណើរអនុវត្តឱ្យបានល្អ ។